រៀបរៀងដោយ លឹម ផល្គុន

បរិញ្ញាបត្រគណិតវិទ្យា និង ពាណិជ្ជកម្ម

គណិតវិទ្យា

សម្រាប់ត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិ

$$f(x)=\begin{cases} \dfrac{\sin x}{x} & \text{បើ } x\neq 0 \\ 1 & \text{បើ } x=0 \end{cases}$$

អ្នកសហការណ៍ត្រួតពិនិត្យបច្ចេកទេស

លោក **លឹម ឆុន**

លោក **សែន ពិសិដ្ឋ**

លោក **និត្យ ម៉េង**

លោកស្រី **ទុយ រីណា**

លោក **ព្រឹម សុខនិត**

លោក **ផល ប៊ុនឆាយ**

អ្នករចនាក្រប និង បច្ចេកទេសកំព្យូទ័រ

កញ្ញា **លី គុណ្ណាកា**

អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក **លឹម មិត្តសិរ**

អារម្ភកថា

សៀវភៅ **ដំណោះស្រាយលំហាត់គណិតវិទ្យា** ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះខ្ញុំបាទបានខិតខំស្រាវជ្រាវ និងនិពន្ធឡើងក្នុងគោលបំណងទុកជាឯកសារស្រាវជ្រាវសម្រាប់អ្នកសិក្សាដែលមានបំណងចង់ចេះចង់ដឹងអំពីមេរៀននេះឱ្យកាន់តែច្បាស់ ។

នៅក្នុងសៀវភៅ នេះបានប្រមូលផ្តុំនូវប្រធានលំហាត់យ៉ាងច្រើននិងមានលក្ខណះខុសប្លែកៗគ្នា ។ប្រធានលំហាត់នីមួយៗខ្ញុំបាទបានខិតខំជ្រើសរើសយ៉ាងសម្រិតសម្រាំងបំផុតព្រមទាំងធ្វើដំណោះស្រាយយ៉ាងក្បោះក្បាយដែលអាចឱ្យអ្នកសិក្សាងាយយល់និងឆាប់ចងចាំអំពីវិធីសាស្ត្រធ្វើដំណោះស្រាយលំហាត់នីមួយៗ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កង្វះខាតបច្ចេកទេសគរុកោសល្យ និង កំហុសអក្ខរាវិរុទ្ធប្រាកដជាកើតមានឡើងដោយអចេតនាជាពុំខានឡើយ ។ អាស្រ័យហេតុនេះខ្ញុំបាទជាអ្នកនិពន្ធ រង់ចាំទទួលនូវមតិរិះគន់បែបស្ថាបនាពីសំណាក់អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយជានិច្ចដើម្បីកែលំអសៀវភៅនេះឱ្យកាន់តែមានសុក្រិត្យភាពថែមទៀត ។

ខ្ញុំបាទជាអ្នកនិពន្ធសង្ឃឹមថាសៀវភៅសិក្សាអនុគមន៍មួយក្បាលនេះនឹងចូលរួមនាំលោកអ្នកឆ្ពោះទៅរកជ័យជំនះក្នុងការសិក្សា និង ការប្រឡងប្រជែងនានាជាពុំខានឡើយ ។

សូមឱ្យអ្នកសិក្សាទាំងអស់មានសុខភាពល្អមានប្រាជ្ញាឈ្លាសវៃ និងមានសំណាងល្អក្នុងឆាកជីវិត និង ការសិក្សា !

បាត់ដំបងថ្ងៃទី ២២ ខែ កុម្ភះ ឆ្នាំ ២០០៨

អ្នកនិពន្ធ និង ស្រាវជ្រាវ លឹម ផល្គុន

មេរៀនទី១

ចំនួនកុំផ្លិច

១_និយមន័យ

ចំនួនដែលមានទម្រង់ $z = a + i.b$ ដែល a និងb ជាចំនួនពិត ហៅថាចំនួនកុំផ្លិច ។

☞ ទម្រង់ $z = a + i.b$ ហៅថាទម្រង់ពីជគណិតនៃចំនួនកុំផ្លិច។

☞ a ហៅថាផ្នែកពិតដែលគេកំនត់សរសេរ $Re(z) = a$ ។

☞ b ហៅថាផ្នែកពិតដែលគេកំនត់សរសេរ $Im(z) = b$ ។

☞ i ហៅថាឯកតានិម្មិតដែល $i^2 = -1$ រឺ $i = \sqrt{-1}$

☞ គេតាងសំណុំចំនួនកុំផ្លិចដោយ $\mathbb{C}$ ។

២_ប្រមាណវិធីលើចំនួនកុំផ្លិច ៖

សន្មតថាគេមានចំនួនកុំផ្លិច $z = a + i.b$ និង $z' = a' + i.b'$ ដែល $a; b; a'; b'$ ជាចំនួនពិត ។

- ផលបូក $z + z' = (a + a') + i.(b + b')$

- ផលដក $z - z' = (a - a') + i(b - b')$

- ផលគុណ $z \times z' = (aa' - bb') + i(ab' + a'b)$

- ចំរាស់ $\frac{1}{z}=\frac{a-i.b}{a^2+b^2}$

- ផលចែក $\frac{z'}{z}=\frac{aa'+bb'}{a^2+b^2}+i.\frac{ab'-a'b}{a^2+b^2}$

៣_ឯកលក្ខណៈភាពគួរកត់សំគាល់

បើ z និង z' ជាពីរចំនួនកុំផ្លិចនោះគេមាន ៖

$(z+z')^2=z^2+2zz'+z'^2$; $(z-z')^2=z^2-2zz'+z'^2$

$z^2-z'^2=(z+z')(z-z')$

$1+z+z^2+...+z^n=\frac{1-z^{n+1}}{1-z}$; $z\neq 1$, $n\in IN^*$

$(z+z')^n=\sum_{k=0}^{n}\left(C_n^k z^k z'^{n-k} \right)$; $n\in IN^*$

៤_ចំនួនកុំផ្លិចឆ្លាស់

ក_ បើគេមានចំនួនកុំផ្លិច $z=a+i.b$ ដែល a និង b ជាចំនួនពិត ។

ចំនួនកុំផ្លិចឆ្លាស់នៃ z តាងដោយ $\bar{z}=a-i.b$ ។

ខ_ លក្ខណៈ

បើ z និង z' ជាពីរចំនួនកុំផ្លិចនោះគេមាន ៖

$\overline{z+z'}=\bar{z}+\overline{z'}$; $\overline{z-z'}=\bar{z}-\overline{z'}$

$\overline{z\times z'}=\bar{z}\times\overline{z'}$; $\overline{\left(\frac{z}{z'}\right)}=\frac{\bar{z}}{\overline{z'}}$

គ_ សំគាល់

បើ $z = a + i.b$ នោះ $\bar{z} = a - i.b$

គេបាន $Re(z) = \frac{z + \bar{z}}{2}$ និង $Im(z) = \frac{z - \bar{z}}{2i}$ ។

៥_ស្វ័យគុណនៃ i

ចំពោះគ្រប់ $k \in IN^*$ គេមាន ៖

$$i^{4k} = 1 \; ; \; i^{4k+1} = i \; ; \; i^{4k+2} = -1 \; ; \; i^{4k+3} = -i$$

៦_ដំណោះស្រាយសមីការដឺក្រេទីពីរ

គេឱ្យសមីការដឺក្រេទីពីរ $az^2 + bz + c = 0 \; ; a \neq 0 , a;b;c \in IR$

_ បើ $\Delta = b^2 - 4ac > 0$

សមីការមានឫសពីរផ្សេងគ្នាជាចំនួនពិតកំនត់ដោយ

$$z_1 = \frac{-b + \sqrt{\Delta}}{2a} \; ; \; z_2 = \frac{-b - \sqrt{\Delta}}{2a}$$ ។

_ បើ $\Delta = b^2 - 4ac = 0$

សមីការមានឫសឌុបមួយជាចំនួនពិតកំនត់ដោយ

$$z_1 = z_2 = -\frac{b}{2a}$$ ។

_ បើ $\Delta = b^2 - 4ac < 0$

សមីការមានឫពីរជាចំនួនកុំផ្លិចឆ្លាស់គ្នាកំនត់ដោយ

$$z_1 = \frac{-b + i\sqrt{|\Delta|}}{2a} \; ; \; z_2 = \frac{-b - i\sqrt{|\Delta|}}{2a}$$ ។

៧_ការតាងចំនួនកុំផ្លិចតាមបែបធរណីមាត្រ

ក_ ចំនុច M នៃប្លង់ប្រកបដោយតម្រុយអរត្ូនរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមាន កូអរដោនេ $(a;b)$ ហៅថាចំនុចរូបភាពនៃ ចំនួនកុំផ្លិច $z=a+i.b$ ។

ចំនួនកុំផ្លិច $z=a+i.b$ ហៅថាអាហ្វិកនៃចំនុច $M(a;b)$ ។



ខ_វ៉ិចទ័រ $\vec{w}$ នៃប្លង់ប្រកបដោយតម្រុយអរត្ូនរម៉ាល់ $(O,\vec{i},\vec{j})$ ដែលមាន កូអរដោនេ $(a;b)$ ហៅថាវិចទ័ររូបភាពនៃ ចំនួនកុំផ្លិច $z=a+i.b$ ។

ចំនួនកុំផ្លិច $z=a+i.b$ ហៅថាអាហ្វិកនៃវ៉ិចទ័រ $\vec{W}(a;b)$ ។



៨_ម៉ូឌុលនៃចំនួនកុំផ្លិចមួយ



ក_ បើគេមានចំនួនកុំផ្លិច $z = a + i.b$ ដែល a និង b ជាចំនួនពិតម៉ូឌុលនៃចំនួនកុំផ្លិចនេះគឺជាចម្ងាយOM កំនត់ដោយ ៖

$|z| = OM = \sqrt{a^2 + b^2}$ ។

ខ_ លក្ខណះ

$$|z| = \sqrt{z\times\bar{z}} \quad ; \quad |z\times z'| = |z|\times|z'| \quad ; \quad \left|\frac{z}{z'}\right| = \frac{|z|}{|z'|}$$ ។

គ_ វិសមភាពត្រីកោណ

ចំពោះគ្រប់ចំនួនកុំផ្លិច z និង z' គេមាន ៖

$|z+z'| \le |z|+|z'|$ ។

ឃ_ ចម្ងាយរវាងពីរចំនុចក្នុងប្លង់

បើ A និង B ជាពីរចំនុចមានអាហ្វិករៀងគ្នា z_A និង z_B នៃប្លង់ប្រកបដោយតម្រុយអរត្តូនរម៉ាល់ $(O,\vec{i},\vec{j})$

គេបាន $d(AB) = |z_B - z_A|$ ។

៩ _ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិចមួយ



គេមានចំនួនកុំផ្លិច $z = a + i.b$ ដែល a និង b ជាពីរចំនួនពិត ទម្រង់ត្រីកោណមាត្រនៃ z កំនត់ដោយ

$$z = r\ (\cos\theta + i.\sin\theta)$$

ដែល $r = \sqrt{a^2 + b^2}$ និង $\cos\theta = \frac{a}{r}$; $\sin\theta = \frac{b}{r}$ ។

១០_ប្រមាណវិធីលើចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ

សន្មតថាគេមានចំនួនកុំផ្លិចត្រីកោណមាត្រពីរ ៖

$z = r(\cos\theta + i.\sin\theta)$ និង $z' = r'(\cos\theta' + i.\sin\theta')$

_ផលគុណ $z \times z' = r.r'\left[\cos(\theta + \theta') + i.\sin(\theta + \theta')\right]$

_ផលចែក $\frac{z}{z'} = \frac{r}{r'}\left[\cos(\theta - \theta') + i.\sin(\theta - \theta')\right]$

១១_ស្វ័យគុណទី n

សន្មតថាគេមានចំនួនកុំផ្លិចត្រីកោណមាត្រ $z = r(\cos\theta + i.\sin\theta)$ ស្វ័យគុណទី n នៃចំនួនកុំផ្លិចនេះកំនត់ដោយ ៖

$z^n = \left[r\ (\cos\theta + i.\sin\theta)\right]^n = r^n\left[\cos(n\theta) + i.\sin(n\theta)\right]$ គ្រប់ $n \in Z$

១២_រូបមន្តដឺម័រ

ចំពោះគ្រប់ $\theta \in IR$; $n \in Z$ គេមាន ៖

$(\cos\theta + i.\sin\theta)^n = \cos(n\theta) + i.\sin(n\theta)$ (ហៅថារូបមន្តដឺម័រ)

១៣_ឫសទី n នៃចំនួនកុំផ្លិចមួយ

បើគេមាន $z = r(\cos\theta + i.\sin\theta)$ ជាចំនួនកុំផ្លិចមិនសូន្យ

និង $n \in IN$ ។ឬសទី n នៃចំនួនកុំផ្លិចនេះកំណត់ដោយ ៖

$$W_k = \sqrt[n]{r}\left[\cos(\frac{\theta + 2k\pi}{n}) + i.\sin(\frac{\theta + 2k\pi}{n})\right] ;\ k = 0, 1, 2, ..., (n-1).$$

១៤_ទម្រង់អ៊ិចស្ប៉ូណង់ស្យែលនៃចំនួនកុំផ្លិចមួយ

បើ z ជាចំនួនកុំផ្លិចមានម៉ូឌុល r និងអាគុយម៉ង់ θ

នោះទម្រង់អ៊ិចស្ប៉ូណង់ស្យែលនៃ z កំនត់ដោយ $z = r.e^{i.\theta}$

១៥_រូបមន្តអឺលែ

ចំពោះគ្រប់ចំនួនពិត θ គេមានទំនាក់ទំនង ៖

$\cos\theta = \frac{e^{i.\theta} + e^{-i.\theta}}{2}$ និង $\sin\theta = \frac{e^{i.\theta} - e^{-i.\theta}}{2i}$ ។

១៦_ទំនាក់ទំនងរវាងទម្រង់ពីជគណិត_ត្រីកោណមាត្រ និង

អ៊ិចស្ប៉ូណង់ស្យែល ៖

$$z = a + i.b = r(\cos\theta + i.\sin\theta) = r.e^{i.\theta}$$

ដែល $r = \sqrt{a^2 + b^2}$; $\cos\theta = \frac{a}{r}$; $\sin\theta = \frac{b}{r}$ ។

✍ ✍ ✍ ✍ ✍

លំហាត់ទី១

គេឱ្យចំនួនកុំផ្លិច $a=2+3i$; $b=-3+i$ និង $c=1-4i$

ក_ ចូរសរសេរ $a^3+b^3+c^3$ និង $a\times b\times c$ ជាទម្រង់ពីជគណិត ។

ខ_ ចូរផ្ទៀងផ្ទាត់ថាគេអាចកំនត់ចំនួនពិត k ដើម្បីឱ្យ

$a^3+b^3+c^3=k.abc$ ។

ដំណោះស្រាយ

ក.សរសេរ $a^3+b^3+c^3$ និង $a\times b\times c$ ជាទម្រង់ពីជគណិត ៖

យើងមាន $a^3=(2+3i)^3=8+36i-54-27i=-46+9i$

$b^3=(-3+i)^3=-27+27i+9-i=-18+26i$

$c^3=(1-4i)^3=1-12i-48+64i=-47+52i$

យើងបាន $a^3+b^3+c^3=-46+9i-18+26i-47+52i=-111+87i$

ដូចនេះ $\boxed{a^3+b^3+c^3=-111+87i}$ ។

យើងមាន $a\times b\times c=(2+3i)(-3+i)(1-4i)$

$=(-6+2i-9i-3)(1-4i)$

$=(-9-7i)(1-4i)$

$=-9+36i-7i-28$

$=-37+29i$

ដូចនេះ $\boxed{a\times b\times c=-37+29i}$ ។

ខ.កំនត់ចំនួនពិត k

យើងមាន $a^3+b^3+c^3=k.abc$

គេទាញ $$k=\frac{a^3+b^3+c^3}{a.b.c}=\frac{-111+87i}{-37+29i}=3$$

ដូចនេះ $k=3$ ។

លំហាត់ទី២

គេឱ្យចំនួនកុំផ្លិច $a=3+i$; $u=(x-1)+i.(y+2)$ និង $b=2-16i$

ដែល x និង y ជាពីរចំនួនពិត ។

ចូរកំនត់តម្លៃ x និង y ដើម្បីឱ្យ $au+b=0$ ។

ដំណោះស្រាយ

កំនត់តម្លៃនៃ x និង y

យើងបាន $au+b=0$

$$u=-\frac{b}{a}$$

ដោយ $a=3+i$; $u=(x-1)+i.(y+2)$ និង $b=2-16i$

គេបាន $(x-1)+i.(y+2)=-\dfrac{2-16i}{3+i}$

$$(x-1)+i(y+2)=-\frac{2(1-8i)(3-i)}{3^2-i^2}$$

$$(x-1)+i(y+2)=-\frac{2(3-i-24i-8)}{10}$$

$$(x-1)+i(y+2)=-\frac{2(-5-25i)}{10}$$

$$(x-1)+i(y+2)=1+5i$$

គេទាញបាន $\begin{cases} x-1=1 \\ y+2=5 \end{cases}$ នាំឱ្យ $x=2\ ;\ y=3$

ដូចនេះ $\boxed{x=2\ ;\ y=3}$ ។

✍✍✍✍✍

លំហាត់ទី៣

គេឱ្យចំនួនកុំផ្លិច $Z=\log_3(\frac{x+y}{2})+i\left(\log_2 x+\log_2 y\right)$

និង $W=\frac{13+i}{1-2i}$ ដែល $x\in IR_+^*$; $y\in IR_+^*$ ។

ក_ ចូរសរសេរ W ជាទម្រង់ពីជគណិត ។

ខ_ កំនត់ x និង y ដើម្បីឱ្យ $Z=W$ ។

ដំណោះស្រាយ

ក_សរសេរ W ជាទម្រង់ពីជគណិត

យើងបាន $W=\frac{12+i}{1-2i}=\frac{(12+i)(1+2i)}{1+4}=\frac{12+24i+i-2}{5}=2+5i$

ដូចនេះ $\boxed{W=2+5i}$ ។

ខ_កំនត់ x និង y ដើម្បីឲ្យ $Z=W$

យើងបាន $Z=W$ សមមូល $\begin{cases}\log_2(\frac{x+y}{3})=2\\ \log_2 x+\log_2 y=5\end{cases}$

ឬ $\begin{cases}\log_2(\frac{x+y}{3})=2\\ \log_2(x.y)=5\end{cases}$ នាំឲ្យ $\begin{cases}x+y=12\\ x.y\ \ =32\end{cases}$

គេទាញ x ; y ជាឬសសមីការ $u^2-12u+32=0$

ដោយ $\Delta'=36-32=4$ គេទាញឬស $\left[\begin{array}{l}u_1=6-2=4\\ u_2=6+2=8\end{array}\right.$

ដូចនេះ $x=4$; $y=8$ ឬ $x=8$; $y=4$ ។

លំហាត់ទី៤

គេឱ្យសមីការ $(E): z^2 + az + b = 0$ ដែល $a;b \in IR$

ចូរកំនត់តម្លៃ a និង b ដើម្បីឱ្យចំនួនកុំផ្លិច $z_1 = 2 + i\sqrt{3}$

ជាឬសរបស់សមីការ (E) រួចទាញរកឬស z_2 មួយទៀត

របស់សមីការ ។

តើអ្នកពិនិត្យឃើញដូចម្តេចចំពោះចំនួនកុំផ្លិច z_1 និង z_2 ?

ដំណោះស្រាយ

កំនត់តម្លៃ a និង b

ដើម្បីឱ្យចំនួនកុំផ្លិច $2 + i\sqrt{3}$ ជាឬសរបស់សមីការលុះត្រាតែ

វាផ្ទៀងផ្ទាត់សមីការ ។

គេបាន $(2 + i\sqrt{3})^2 + a(2 + i\sqrt{3}) + b = 0$

$$4 + 4i\sqrt{3} - 3 + 2a + ai\sqrt{3} + b = 0$$

$$(1 + 2a + b) + i(4\sqrt{3} + a\sqrt{3}) = 0$$

គេទាញបាន $\begin{cases} 4\sqrt{3} + a\sqrt{3} = 0 \\ 1 + 2a + b = 0 \end{cases}$ ឬ $\begin{cases} a = -4 \\ b = 7 \end{cases}$

ដូចនេះ $\boxed{a = -4\,;\ b = 7}$ ។

គណនាឬសមួយទៀតរបស់សមីការ ៖

បើ z_1 ; z_2 ជាឬសរបស់សមីការនោះតាមទ្រឹស្តីបទវ្យែតគេបាន

$z_1 + z_2 = -a = 4$ ដោយ $z_1 = 2 + i\sqrt{3}$

គេទាញ $z_2 = 4-(2+i\sqrt{3}) = 2-i\sqrt{3}$

ដូចនេះ $z_2 = 2-i\sqrt{3}$ ។

យើងពិនិត្យឃើញថា $z_1 = 2+i\sqrt{3}$ និង $z_2 = 2-i\sqrt{3}$

ជាចំនួនកុំផ្លិចពីរឆ្លាស់គ្នា ។

លំហាត់ទី៥

គេឱ្យចំនួនកុំផ្លិច z ដែលមាន $\bar{z}$ ជាចំនួនកុំផ្លិចឆ្លាស់របស់វា

ដោះស្រាយសមីការ $\log_5|z| + \dfrac{z+i\,\bar{z}}{7} = 3+i$

ដំណោះស្រាយ

ដោះស្រាយសមីការ ៖

$$\log_5|z| + \frac{z+i\bar{z}}{7} = 3+i$$

តាង $z = x+i.y$ នាំឲ្យ $\bar{z} = x-iy$ ដែល $x\,;\,y \in IR$

សមីការអាចសរសេរ ៖

$$\log_5|x+iy| + \frac{(x+iy)+i(x-iy)}{7} = 3+i$$

$$\log_5\sqrt{x^2+y^2} + \frac{x+iy+ix+y}{7} = 3+i$$

$$\left(\frac{x+y}{7} + \log_5\sqrt{x^2+y^2}\right) + i\,\frac{x+y}{7} = 3+i$$

គេទាញបាន $\begin{cases} \dfrac{x+y}{7}=1 \\ \dfrac{x+y}{7}+\log_5\sqrt{x^2+y^2}=3 \end{cases}$ ឬ $\begin{cases} x+y=7 \\ 1+\log_5\sqrt{x^2+y^2}=3 \end{cases}$

ឬ $\begin{cases} x+y=7 \\ x^2+y^2=25 \end{cases}$ ដោយ $x^2+y^2=(x+y)^2-2xy$ នាំឲ្យ $xy=12$

គេបានប្រព័ន្ធ $\begin{cases} x+y=7=3+4 \\ x.y=12=3\times 4 \end{cases}$

គេទាញចម្លើយ $x=3\ ,\ y=4$ ឬ $x=4\ ,\ y=3$

ដូចនេះ $z_1=3+4i\ \ ;\ z_2=4+3i$ ជាចម្លើយរបស់សមីការ ។

លំហាត់ទី៦

គេឱ្យចំនួនកុំផ្លិចពីរ ៖

$z=3x-i\,(2x-y)$ និង $W=-1+y+i\,[\ 1+2^{\log_5(x+3)}\ ]$

ដែល x និង y ជាចំនួនពិត ។

កំនត់ x និង y ដើម្បីឱ្យ $W=z$ ។

ដំណោះស្រាយ

កំនត់ x និង y

ដើម្បីឱ្យ $W=z$ លុះត្រាតែ $\begin{cases} \mathrm{Re}(W)=\mathrm{Re}(z) \\ \mathrm{Im}(W)=\mathrm{Im}(z) \end{cases}$

គេទាញបាន $\begin{cases} -1+y=3x & (1) \\ 1+2^{\log_5(x+3)}=-2x+y & (2) \end{cases}$

តាម (1) គេទាញ $y=3x+1$ (3) យកជំនួសក្នុងសមីការ (2)

គេបាន $1+2^{\log_5(x+3)}=-2x+3x+1$

$2^{\log_5(x+3)}=x$ លក្ខខ័ណ្ឌ $x+3>0$ ឬ $x>-3$

តាង $t=\log_5(x+3)$ នាំឱ្យ $x+3=5^t$ ឬ $x=5^t-3$

គេបានសមីការ $2^t=5^t-3$ ឬ $5^t-2^t=3$

ដោយអង្គខាងឆ្វេងនៃសមីការជាអនុគមន៍កើន និង អង្គខាងឆ្វេង ជាអនុគមន៍ថេរនោះយើងបានសមីការមានឫសតែមួយគត់គឺ $t=1$

ចំពោះ $t=1$ គេបាន $x=5-3=2$ និង $y=3(2)+1=7$

ដូចនេះ $\boxed{x=2\ ;\ y=7}$ ។

លំហាត់ទី៧

ដោះស្រាយសមីការ $2z-|z|=\frac{9-7i}{1+i}$ ដែល z ជាចំនួនកុំផ្លិច ។

ដំណោះស្រាយ

ដោះស្រាយសមីការ ៖

$2z-|z|=\frac{9-7i}{1+i}$ តាង $z=x+i.y\ ,\ x;y\in IR$

គេបាន $2(x+iy)-|x+iy|=\frac{(9-7i)(1-i)}{(1+i)(1-i)}$

$$2x+2iy-\sqrt{x^2+y^2}=\frac{9-9i-7i-7}{2}$$

$$(2x-\sqrt{x^2+y^2})+2iy=1-8i$$

គេទាញ $\begin{cases} 2x-\sqrt{x^2+y^2}=1 & (1) \\ 2y=-8 & (2) \end{cases}$

តាម (2) គេទាញ $y=-4$ យកទៅជួសក្នុង (1) គេបាន

$2x-\sqrt{x^2+16}=1$

$$2x-1=\sqrt{x^2+16}\quad ,\ x>-\frac{1}{2}$$

$$(2x-1)^2=x^2+16$$

$$4x^2-4x+1=x^2+16$$

$$3x^2-4x-15=0\quad ;\ \Delta'=4+45=7^2$$

គេទាញឬស $x_1=\frac{2+7}{3}=3\ ;\ x_2=\frac{2-7}{3}=-\frac{5}{3}<-\frac{1}{2}$ (មិនយក)

គេបាន $x=3\ ;\ y=-4$ ។

ដូចនេះ $\boxed{z=3-4i}$ ជាចម្លើយរបស់សមីការ ។

លំហាត់ទី៨

គេឱ្យចំនួនកុំផ្លិចពីរ Z_1 និង Z_2 ដែល $Z_2 \neq 0$ ។

ចូរស្រាយបញ្ជាក់ថា $\left|\frac{Z_1}{Z_2}\right| = \frac{|Z_1|}{|Z_2|}$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\left|\frac{Z_1}{Z_2}\right| = \frac{|Z_1|}{|Z_2|}$

យើងតាង $Z_1 = a + i.b$ និង $Z_2 = c + i.d$ ដែល a, b, c, d ជាចំនួនពិត ។

យើងបាន $\frac{Z_1}{Z_2} = \frac{a+i.b}{c+i.d} = \frac{(a+i.b)(c-i.d)}{(c+i.d)(c-i.d)} = \frac{ac - i.ad + i.bc - i^2.bd}{c^2 - i^2.d^2}$ តែ $i^2 = -1$

គេបាន $\frac{Z_1}{Z_2} = \frac{(ac+bd)+i(bc-ad)}{c^2+d^2} = \frac{ac+bd}{c^2+d^2} + i.\frac{bc-ad}{c^2+d^2}$

នាំឱ្យ $$\left|\frac{Z_1}{Z_2}\right| = \sqrt{\left(\frac{ac+bd}{c^2+d^2}\right)^2 + \left(\frac{bc-ad}{c^2+d^2}\right)^2}$$

$$= \frac{\sqrt{(ac+bd)^2 + (bc-ad)^2}}{c^2+d^2}$$

$$= \frac{\sqrt{a^2c^2 + 2abcd + b^2d^2 + b^2c^2 - 2abcd + a^2d^2}}{c^2+d^2}$$

$$= \frac{\sqrt{(a^2c^2 + a^2d^2) + (b^2c^2 + b^2d^2)}}{c^2+d^2}$$

$$= \frac{\sqrt{a^2(c^2+d^2) + b^2(c^2+d^2)}}{c^2+d^2} = \frac{\sqrt{(c^2+d^2)(a^2+b^2)}}{c^2+d^2}$$

គេទាញ $\left|\frac{Z_1}{Z_2}\right| = \frac{\sqrt{a^2+b^2}}{\sqrt{c^2+d^2}}$ ដោយគេមាន $\begin{cases} |Z_1| = \sqrt{a^2+b^2} \\ |Z_2| = \sqrt{c^2+d^2} \end{cases}$

ដូច្នេះ $\boxed{\left|\frac{Z_1}{Z_2}\right| = \frac{|Z_1|}{|Z_2|}}$ ។

លំហាត់ទី៩

គេឱ្យចំនួនកុំផ្លិចពីរ Z_1 និង Z_2 ។

ចូរស្រាយបញ្ជាក់ថា $|Z_1 \times Z_2| = |Z_1| \times |Z_2|$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $|Z_1 \times Z_2| = |Z_1| \times |Z_2|$

យើងតាង $Z_1 = a + i.b$ និង $Z_2 = c + i.d$ ដែល a, b, c, d ជាចំនួនពិត ។

យើងមាន $Z_1 \times Z_2 = (a+i.b)(c+i.d) = ac + i.ad + i.bc + i^2.bd$ តែ $i^2 = -1$

នាំឱ្យ $Z_1 \times Z_2 = (ac - bd) + i.(ad + bc)$

គេបាន
$$|Z_1 \times Z_2| = \sqrt{(ac-bd)^2 + (ad+bc)^2}$$
$$= \sqrt{a^2c^2 - 2abcd + b^2d^2 + a^2d^2 + 2abcd + b^2c^2}$$
$$= \sqrt{(a^2c^2 + b^2c^2) + (a^2d^2 + b^2d^2)}$$
$$= \sqrt{c^2(a^2+b^2) + d^2(a^2+b^2)}$$
$$= \sqrt{(a^2+b^2)(c^2+d^2)}$$

គេទាញ $|Z_1 \times Z_2| = \sqrt{a^2+b^2} \times \sqrt{c^2+d^2}$

ដោយគេមាន $\begin{cases} |Z_1| = \sqrt{a^2+b^2} \\ |Z_2| = \sqrt{c^2+d^2} \end{cases}$

ដូចនេះ $\boxed{|Z_1 \times Z_2| = |Z_1| \times |Z_2|}$ ។

លំហាត់ទី១០

គេឱ្យចំនួនកុំផ្លិចពីរ Z_1 និង Z_2 ។

ក. ចូរស្រាយបញ្ជាក់ថា $|Z_1+Z_2| \le |Z_1|+|Z_2|$

ខ. ទាញឱ្យបានថា $\sqrt{(a+c)^2+(b+d)^2} \le \sqrt{a^2+b^2}+\sqrt{c^2+d^2}$

ចំពោះគ្រប់ a,b,c,d ជាចំនួនពិត ។

ដំណោះស្រាយ

ក. ស្រាយបញ្ជាក់ថា $|Z_1+Z_2| \le |Z_1|+|Z_2|$

ក្នុងប្លង់កុំផ្លិច (XOY) យើងជ្រើសរើសវ៉ិចទ័រពីរ $\vec{U}$ និង $\vec{V}$ មានអាហ្វិករៀងគ្នា Z_1 និង Z_2 នាំឱ្យវ៉ិចទ័រ $\vec{U}+\vec{V}$ មានអាហ្វិក Z_1+Z_2 ។

តាមលក្ខណៈជ្រុងរបស់ត្រីកោណគេបាន $\|\vec{U}+\vec{V}\| \le \|\vec{U}\|+\|\vec{V}\|$

ដោយ :

$\|\vec{U}\| = |Z_1|$, $\|\vec{V}\| = |Z_2|$

$\|\vec{U}+\vec{V}\| = |Z_1+Z_2|$

ដូចនេះ $\boxed{|Z_1+Z_2| \le |Z_1|+|Z_2|}$

ខ. ទាញឱ្យបានថា $\sqrt{(a+c)^2+(b+d)^2} \le \sqrt{a^2+b^2}+\sqrt{c^2+d^2}$

យើងតាង $Z_1 = a+i.b$ និង $Z_2 = c+i.d$ ដែល a,b,c,d ជាចំនួនពិត ។

មាន $Z_1+Z_2 = (a+c)+i.(b+d)$ នាំឱ្យ $|Z_1+Z_2| = \sqrt{(a+c)^2+(b+d)^2}$

ហើយ $|Z_1| = \sqrt{a^2+b^2}$, $|Z_2| = \sqrt{c^2+d^2}$ ។

តាមសម្រាយខាងលើគេមាន $|Z_1+Z_2| \le |Z_1|+|Z_2|$

ដូចនេះ $\boxed{\sqrt{(a+c)^2+(b+d)^2} \le \sqrt{a^2+b^2}+\sqrt{c^2+d^2}}$ ។

លំហាត់ទី១១

គេឱ្យចំនួនកុំផ្លិច :

$Z_1 = 3+4i$, $Z_2 = 12+5i$, $Z_3 = -8+15i$

ក. ចូរគណនា $|Z_1|, |Z_2|, |Z_3|$ និង $|Z_1+Z_2+Z_3|$

ខ. ទាញបង្ហាញថា $|Z_1+Z_2+Z_3| < |Z_1|+|Z_2|+|Z_3|$

និង $|Z_1|+|Z_1+Z_2+Z_3| = |Z_2|+|Z_3|$ ។

ដំណោះស្រាយ

ក. គណនា $|Z_1|, |Z_2|, |Z_3|$ និង $|Z_1+Z_2+Z_3|$

យើងបាន $|Z_1| = \sqrt{3^2+4^2} = \sqrt{9+16} = \sqrt{25} = 5$

$|Z_2| = \sqrt{12^2+5^2} = \sqrt{144+25} = \sqrt{169} = 13$

$|Z_3| = \sqrt{(-8)^2+(15)^2} = \sqrt{64+225} = \sqrt{289} = 17$

ហើយ $Z_1+Z_2+Z_3 = (3+4i)+(12+5i)+(-8+15i) = 7+24i$

គេបាន $|Z_1+Z_2+Z_3| = \sqrt{7^2+24^2} = \sqrt{49+576} = \sqrt{625} = 25$

ដូចនេះ $|Z_1| = 5$, $|Z_2| = 13$, $|Z_3| = 17$ និង $|Z_1+Z_2+Z_3| = 25$ ។

ខ. ទាញបង្ហាញថា ៖

$$|Z_1+Z_2+Z_3| < |Z_1|+|Z_2|+|Z_3|$$

និង $|Z_1|+|Z_1+Z_2+Z_3| = |Z_2|+|Z_3|$

យើងមាន $|Z_1+Z_2+Z_3| = 25$

ហើយ $|Z_1|+|Z_2|+|Z_3| = 5+13+17=35$

ដូចនេះ $|Z_1+Z_2+Z_3| < |Z_1|+|Z_2|+|Z_3|$ ។

ម្យ៉ាងទៀត $|Z_1|+|Z_1+Z_2+Z_3| = 5+25=30$

និង $|Z_2|+|Z_3| = 13+17=30$

ដូចនេះ $|Z_1|+|Z_1+Z_2+Z_3| = |Z_2|+|Z_3|$ ។

លំហាត់ទី១២

គេឱ្យសមីការ $(E): z^2+az+b=0$, $a, b \in IR$

ចូរកំនត់ចំនួនពិត a និង b ដើម្បីឱ្យចំនួនកុំផ្លិច $z=3+2i$ ជាឬសរបស់សមីការរួចគណនាឬសមួយទៀតរបស់សមីការ ។

ដំណោះស្រាយ

កំនត់ចំនួនពិត a និង b ៖

ដើម្បីឱ្យចំនួនកុំផ្លិច $z=3+2i$ ជាឬសរបស់សមីការលុះត្រាតែវាផ្ទៀងផ្ទាត់នឹងសមីការ ។

យើងបាន $(3+2i)^2+a(3+2i)+b=0$

$$9+12i+4i^2+3a+2ia+b=0 \quad , \ i^2=-1$$

$$9+12i-4+3a+2ia+b=0$$

$$(5+3a+b)+i(12+2a)=0$$

គេទាញបាន $\begin{cases} 12+2a=0 \\ 5+3a+b=0 \end{cases}$ នាំឱ្យ $a=-6 \ , \ b=13$

ដូចនេះ $\boxed{a=-6 \ , \ b=13}$ ។

គណនាឬសមួយទៀតរបស់សមីការ :

ចំពោះ $a=-6 \ , \ b=13$ សមីការក្លាយជា $Z^2-6Z+13=0$

តាមទ្រឹស្តីបទវ្យែតយើងមាន $Z_1+Z_2=6$ ដោយគេស្គាល់ $Z_1=3+2i$

គេបាន $Z_2=6-Z_1=6-(3+2i)=3-2i$

ដូចនេះឬសមួយទៀតនៃសមីការគឺ $Z_2=3-2i$ ។

លំហាត់ទី១៣

គេឱ្យចំនួនកុំផ្លិច $z=\sqrt{2+\sqrt{2}}+i.\sqrt{2-\sqrt{2}}$ ។

ក.ចូរសរសេរ z^2 ជាទំរង់ពិជគណិត ។

ខ.ចូរសរសេរ z^2 និង z ជាទំរង់ត្រីកោណមាត្រ ។

គ.ទាញរកតំលៃប្រាកដនៃ $\cos\frac{\pi}{8}$ និង $\sin\frac{\pi}{8}$ ។

ដំណោះស្រាយ

ក-សរសេរ z^2 ជាទំរង់ពិជគណិត

យើងបាន $z^2=(\sqrt{2+\sqrt{2}}+i.\sqrt{2-\sqrt{2}})^2$

$$=(\sqrt{2+\sqrt{2}})^2+2(\sqrt{2+\sqrt{2}})(i.\sqrt{2-\sqrt{2}})+(i.\sqrt{2-\sqrt{2}})^2$$

$$=2+\sqrt{2}+2\sqrt{2^2-2}.i-2+\sqrt{2}=2\sqrt{2}+2\sqrt{2}i$$

ដូចនេះ $\boxed{z^2=2\sqrt{2}+2\sqrt{2}.i}$

ខ-ចូរសរសេរ z^2 និង z ជាទំរង់ត្រីកោណមាត្រ

គេមាន $z^2=2\sqrt{2}+2\sqrt{2}.i=4\left(\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2}\right)=4\left(\cos\frac{\pi}{4}+i.\sin\frac{\pi}{4}\right)$

ដូចនេះ $z^2=4\left(\cos\frac{\pi}{4}+i.\sin\frac{\pi}{4}\right)$ និង $z=2\left(\cos\frac{\pi}{8}+i.\sin\frac{\pi}{8}\right)$

គ-ទាញរកតំលៃប្រាកដនៃ $\cos\frac{\pi}{8}$ និង $\sin\frac{\pi}{8}$

តាមសំរាយខាងលើគេទាញ $2\left(\cos\frac{\pi}{8}+i.\sin\frac{\pi}{8}\right)=\sqrt{2+\sqrt{2}}+i.\sqrt{2-\sqrt{2}}$

ដូចនេះ $\boxed{\cos\frac{\pi}{8}=\frac{\sqrt{2+\sqrt{2}}}{2} \quad \text{និង} \quad \sin\frac{\pi}{8}=\frac{\sqrt{2-\sqrt{2}}}{8}}$ ។

លំហាត់ទី១៤

គេអោយចំនួនកុំផ្លិច : $z_1 = \dfrac{\sqrt{6}-i.\sqrt{2}}{2}$ និង $z_2 = 1-i$

ក.ចូរសរសេរ z_1 ,z_2 និង $Z = \dfrac{z_1}{z_2}$ ជារាងត្រីកោណមាត្រ ។

ខ.ចូរសរសេរ $Z = \dfrac{z_1}{z_2}$ ជារាងពិជគណិត ។

គ.ទាញអោយបានថា $\cos\dfrac{\pi}{12} = \dfrac{\sqrt{6}+\sqrt{2}}{4}$ និង $\sin\dfrac{\pi}{12} = \dfrac{\sqrt{6}-\sqrt{2}}{4}$ ។

ដំណោះស្រាយ

ក.សរសេរ z_1 ,z_2 និង $Z = \dfrac{z_1}{z_2}$ ជារាងត្រីកោណមាត្រ:

គេមាន $z_1 = \dfrac{\sqrt{6}-i\sqrt{2}}{2} = \sqrt{2}\left(\dfrac{\sqrt{3}}{2} - i.\dfrac{1}{2}\right) = \sqrt{2}\left(\cos\dfrac{\pi}{6} - i.\sin\dfrac{\pi}{6}\right)$

ដូចនេះ $\boxed{z_1 = \sqrt{2}\left[\cos(-\dfrac{\pi}{6}) + i.\sin(-\dfrac{\pi}{6})\right]}$ ។

គេមាន $z_2 = 1-i = \sqrt{2}\left(\dfrac{\sqrt{2}}{2} - i.\dfrac{\sqrt{2}}{2}\right) = \sqrt{2}\left(\cos\dfrac{\pi}{4} - i.\sin\dfrac{\pi}{4}\right)$

ដូចនេះ $\boxed{z_2 = \sqrt{2}\left[\cos(-\dfrac{\pi}{4}) + i.\sin(-\dfrac{\pi}{4})\right]}$ ។

គេមាន $Z = \dfrac{z_1}{z_2} = \dfrac{\sqrt{2}}{\sqrt{2}}\left[\cos(-\dfrac{\pi}{6}+\dfrac{\pi}{4}) + i.\sin(-\dfrac{\pi}{6}+\dfrac{\pi}{4})\right]$

ដូចនេះ $\boxed{Z = \cos\dfrac{\pi}{12} + i.\sin\dfrac{\pi}{12}}$ ។

ខ. សរសេរ $Z = \dfrac{z_1}{z_2}$ ជារាងពិជគណិត

គេបាន $Z = \dfrac{\sqrt{6}-i\sqrt{2}}{2(1-i)} = \dfrac{(\sqrt{6}-i\sqrt{2})(1+i)}{2(1-i)(1+i)} = \dfrac{\sqrt{6}+i\sqrt{6}-i\sqrt{2}+\sqrt{2}}{4}$

ដូចនេះ $\boxed{Z = \frac{\sqrt{6}+\sqrt{2}}{4} + i.\frac{\sqrt{6}-\sqrt{2}}{4}}$ ។

គ. ទាញអោយបានថា ៖

$\cos\frac{\pi}{12} = \frac{\sqrt{6}+\sqrt{2}}{4}$ និង $\sin\frac{\pi}{12} = \frac{\sqrt{6}-\sqrt{2}}{4}$

តាមសម្រាយខាងលើគេមាន ៖

$$Z = \cos\frac{\pi}{12} + i.\sin\frac{\pi}{12} \quad (1)$$

និង $Z = \frac{\sqrt{6}+\sqrt{2}}{4} + i.\frac{\sqrt{6}-\sqrt{2}}{4} \quad (2)$

ផ្ទឹមទំនាក់ទំនង (1) និង (2) គេបាន ៖

$$\cos\frac{\pi}{12} + i.\sin\frac{\pi}{12} = \frac{\sqrt{6}+\sqrt{2}}{4} + i.\frac{\sqrt{6}-\sqrt{2}}{4}$$

ដូចនេះ $\boxed{\cos\frac{\pi}{12} = \frac{\sqrt{6}+\sqrt{2}}{4}}$ និង $\boxed{\sin\frac{\pi}{12} = \frac{\sqrt{6}-\sqrt{2}}{4}}$ ។

លំហាត់ទី១៥

គេឱ្យចំនួនកុំផ្លិច $z=\sqrt{2+\sqrt{2+\sqrt{3}}}+i.\sqrt{2-\sqrt{2+\sqrt{3}}}$

ក-ចូរបង្ហាញថា $z=2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})$ ។

ខ-ចូរសរសេរ $Z=\frac{z^2}{2+z}$ ជាទម្រង់ត្រីកោណមាត្រ ។

គ-ចូរគណនាតម្លៃនៃ $S_n=z^n+\bar{z}^n$ ជាអនុគមន៍នៃ n ។

ដំណោះស្រាយ

ក-បង្ហាញថា $z=2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})$

គេមាន $z=\sqrt{2+\sqrt{2+\sqrt{3}}}+i.\sqrt{2-\sqrt{2+\sqrt{3}}}$

តាង $a=\sqrt{2+\sqrt{2+\sqrt{3}}}$ និង $b=\sqrt{2-\sqrt{2+\sqrt{3}}}$

យើងបាន $a=\sqrt{2+\sqrt{2+2.\frac{\sqrt{3}}{2}}}$

$$=\sqrt{2+\sqrt{2+2\cos\frac{\pi}{6}}}=\sqrt{2+\sqrt{2(1+\cos\frac{\pi}{6})}}$$

$$=\sqrt{2+\sqrt{4\cos^2\frac{\pi}{12}}}=\sqrt{2+2\cos\frac{\pi}{12}}=\sqrt{4\cos^2\frac{\pi}{24}}=2\cos\frac{\pi}{24}$$

ម្យ៉ាងទៀត $b=\sqrt{2-\sqrt{2+\sqrt{3}}}$

$$=\sqrt{2-2\cos\frac{\pi}{12}}=\sqrt{4\sin^2\frac{\pi}{24}}=2\sin\frac{\pi}{24}$$

គេបាន $z=2\cos\frac{\pi}{24}+2i.\sin\frac{\pi}{24}=2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})$

ដូចនេះ $\boxed{z=2\left(\cos\frac{\pi}{24}+i.\sin\frac{\pi}{24}\right)}$ ។

ខ-សរសេរ $Z=\dfrac{z^2}{2+z}$ ជាទម្រង់ត្រីកោណមាត្រ ៖

យើងមាន $z=2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})$

យើងបាន $$Z=\frac{[2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})]^2}{2+2(\cos\frac{\pi}{24}+i.\sin\frac{\pi}{24})}$$

$$=\frac{4(\cos\frac{\pi}{12}+i.\sin\frac{\pi}{12})}{2(1+\cos\frac{\pi}{24}+i.\sin\frac{\pi}{24})}=\frac{2(\cos\frac{\pi}{12}+i.\sin\frac{\pi}{12})}{2\cos^2\frac{\pi}{48}+2i.\sin\frac{\pi}{48}.\cos\frac{\pi}{48}}$$

$$=\frac{2(\cos\frac{\pi}{12}+i.\sin\frac{\pi}{12})}{2\cos\frac{\pi}{48}(\cos\frac{\pi}{48}+i.\sin\frac{\pi}{48})}$$

$$=\frac{1}{\cos\frac{\pi}{48}}\left[\cos(\frac{\pi}{12}-\frac{\pi}{48})+i.\sin(\frac{\pi}{12}-\frac{\pi}{48})\right]$$

$$=\frac{1}{\cos\frac{\pi}{48}}\left(\cos\frac{3\pi}{48}+i.\sin\frac{3\pi}{48}\right)=\frac{1}{\cos\frac{\pi}{48}}\left(\cos\frac{\pi}{16}+i.\sin\frac{\pi}{16}\right)$$

ដូចនេះ $\boxed{Z=\frac{1}{\cos\frac{\pi}{48}}\left(\cos\frac{\pi}{16}+i.\sin\frac{\pi}{16}\right)}$ ។

គ-គណនាតម្លៃនៃ $S_n=z^n+\overline{z}^n$

តាមរូបមន្តដឺម័រយើងមាន ៖

$z^n=2^n\left(\cos\frac{n\pi}{24}+i.\sin\frac{n\pi}{24}\right)$ និង $\overline{z}^n=2^n\left(\cos\frac{n\pi}{24}-i.\sin\frac{n\pi}{24}\right)$

យើងបាន $S_n=2^n\left(\cos\frac{n\pi}{24}+i.\sin\frac{n\pi}{24}\right)+2^n\left(\cos\frac{n\pi}{24}-i.\sin\frac{n\pi}{24}\right)$

ដូចនេះ $\boxed{S_n=2^{n+1}.\cos\frac{n\pi}{24}}$ ។

លំហាត់ទី១៦

គេឱ្យចំនួនកុំផ្លិច $Z=\cos\frac{4\pi}{5}+i.\sin\frac{4\pi}{5}$

ចូរស្រាយបញ្ជាក់ថា $(1+Z)^3=8\cos^3\frac{2\pi}{5}(\cos\frac{6\pi}{5}+i.\sin\frac{6\pi}{5})$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា :

$$(1+Z)^3=8\cos^3\frac{2\pi}{5}(\cos\frac{6\pi}{5}+i.\sin\frac{6\pi}{5})$$

យើងមាន $1+Z=1+\cos\frac{4\pi}{5}+i.\sin\frac{4\pi}{5}$

តាមរូបមន្ត $1+\cos\theta=2\cos^2\frac{\theta}{2}$ និង $\sin\theta=2\sin\frac{\theta}{2}\cos\frac{\theta}{2}$

យើងបាន $1+Z=2\cos^2\frac{2\pi}{5}+2i\sin\frac{2\pi}{5}\cos\frac{2\pi}{5}$

ឬ $1+Z=2\cos\frac{2\pi}{5}(\cos\frac{2\pi}{5}+i.\sin\frac{2\pi}{5})$

តាមរូបមន្តដឺម័រយើងបាន :

$$(1+Z)^3=\left[2\cos\frac{2\pi}{5}(\cos\frac{2\pi}{5}+i.\sin\frac{2\pi}{5})\right]^3$$

$$=8\cos^3\frac{2\pi}{5}(\cos\frac{6\pi}{5}+i.\sin\frac{6\pi}{5})$$

ដូចនេះ $\boxed{(1+Z)^3=8\cos^3\frac{2\pi}{5}(\cos\frac{6\pi}{5}+i.\sin\frac{6\pi}{5})}$ ។

លំហាត់ទី១៧ គេឱ្យចំនួនកុំផ្លិច $Z=4\sqrt{2}(-1+i)$

ក-ចូរសរសេរ Z ជាទម្រង់ត្រីកោណមាត្រ ។

ខ-គណនាឫសទី3 នៃ Z ។

ដំណោះស្រាយ

ក-សរសេរ Z ជាទម្រង់ត្រីកោណមាត្រ :

យើងបាន $Z=4\sqrt{2}(-1+i)$

$$=8(-\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2})=8(-\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$$

$$=8\left[\cos(\pi-\frac{\pi}{4})+i.\sin(\pi-\frac{\pi}{4})\right]=8(\cos\frac{3\pi}{4}+i.\sin\frac{3\pi}{4})$$

ដូចនេះ $\boxed{Z=8\,(\cos\frac{3\pi}{4}+i.\sin\frac{3\pi}{4})}$ ។

ខ-គណនាឫសទី3 នៃ Z

យើងតាង W_k ជាឫសទី3 នៃ $Z=8\,(\cos\frac{3\pi}{4}+i.\sin\frac{3\pi}{4})$

តាមរូបមន្តឫសទី n : $W_k=\sqrt[n]{r}\left[\cos(\frac{\theta+2k\pi}{n})+i.\sin(\frac{\theta+2k\pi}{n})\right]$

យើងបាន $W_k=\sqrt[3]{8}\left[\cos(\frac{\frac{3\pi}{4}+2k\pi}{3})+i.\sin(\frac{\frac{3\pi}{4}+2k\pi}{3})\right]$

-បើ $k=0$: $W_0=2(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$

-បើ $k=1$: $W_1=2(\cos\frac{11\pi}{12}+i\sin\frac{11\pi}{12})$

-បើ $k=2$: $W_2=2\,(\cos\frac{19\pi}{12}+i.\sin\frac{19\pi}{12})$ ។

លំហាត់ទី១៨

ចូរគណនាឫសទី n នៃចំនួនកុំផ្លិច $Z=-1$

ចំពោះ $n=2\ ,\ 3\ ,4\ ,5\ ,6$ ។

ដំណោះស្រាយ

គណនាឫសទី n នៃចំនួនកុំផ្លិច $Z=-1$

ចំពោះ $n=2\ ,\ 3\ ,4\ ,5\ ,6$

យើងមាន $Z=-1=\cos(\pi+2k\pi)+i.\sin(\pi+2k\pi)$

តាង W_k ជាឫសទី n នៃ Z យើងបាន :

$$W_k=\cos\frac{(1+2k)\pi}{n}+i.\sin\frac{(1+2k)\pi}{n}$$

ក. ចំពោះ $n=2$ គេបាន $W_k=\cos\frac{(1+2k)\pi}{2}+i.\sin\frac{(1+2k)\pi}{2}$

-បើ $k=0:\ W_0=\cos\frac{\pi}{2}+i.\sin\frac{\pi}{2}=i$

-បើ $k=1:\ W_1=\cos\frac{3\pi}{2}+i.\sin\frac{3\pi}{2}=-i$

ខ. ចំពោះ $n=3$ គេបាន $W_k=\cos\frac{(2k+1)\pi}{3}+i.\sin\frac{(2k+1)\pi}{3}$

-បើ $k=0\ :W_0=\cos\frac{\pi}{3}+i.\sin\frac{\pi}{3}=\frac{1}{2}+i.\frac{\sqrt{3}}{2}$

-បើ $k=1:\ W_1=\cos\pi+i.\sin\pi=-1$

-បើ $k=2\ :W_2=\cos\frac{5\pi}{3}+i\sin\frac{5\pi}{3}=\frac{1}{2}-i.\frac{\sqrt{3}}{2}$

គ. ចំពោះ $n=4$ គេបាន $W_k=\cos\frac{(2k+1)\pi}{4}+i.\sin\frac{(2k+1)\pi}{4}$

-បើ $k=0\ :W_0=\cos\frac{\pi}{4}+i.\sin\frac{\pi}{4}=\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2}$

-បើ $k=1\ : W_1=\cos\frac{3\pi}{4}+i.\sin\frac{3\pi}{4}=-\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}$

-បើ $k=2\ : W_2=\cos\frac{5\pi}{4}+i.\sin\frac{5\pi}{4}=-\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}$

-បើ $k=3 : W_3=\cos\frac{7\pi}{4}+i.\sin\frac{7\pi}{4}=\frac{\sqrt{2}}{2}-i.\frac{\sqrt{2}}{2}$

ឃ. ចំពោះ $n=5$ គេបាន $W_k=\cos\frac{(1+2k)\pi}{5}+i.\sin\frac{(1+2k)\pi}{5}$

-បើ $k=0\ : W_0=\cos\frac{\pi}{5}+i.\sin\frac{\pi}{5}$

-បើ $k=1\ : W_1=\cos\frac{3\pi}{5}+i.\sin\frac{3\pi}{5}$

-បើ $k=2 : W_2=\cos\pi+i.\sin\pi=-1$

-បើ $k=3\ : W_3=\cos\frac{7\pi}{5}+i.\sin\frac{7\pi}{5}$

-បើ $k=4 : W_4=\cos\frac{9\pi}{5}+i.\sin\frac{9\pi}{5}$

ង. ចំពោះ $n=6$ គេបាន $W_k=\cos\frac{(1+2k)\pi}{6}+i.\sin\frac{(1+2k)\pi}{6}$

-បើ $k=0 : W_0=\cos\frac{\pi}{6}+i\sin\frac{\pi}{6}=\frac{\sqrt{3}}{2}+i\frac{1}{2}$

-បើ $k=1 : W_1=\cos\frac{\pi}{2}+i.\sin\frac{\pi}{2}=i$

-បើ $k=2 : W_2=\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}=-\frac{\sqrt{3}}{2}+i\frac{1}{2}$

-បើ $k=3 : W_3=\cos\frac{7\pi}{6}+i.\sin\frac{7\pi}{6}=-\frac{\sqrt{3}}{2}-i\frac{1}{2}$

-បើ $k=4 : W_4=\cos\frac{3\pi}{2}+i.\sin\frac{3\pi}{2}=-i$

-បើ $k=5\ : W_5=\cos\frac{11\pi}{6}+i.\sin\frac{11\pi}{6}=\frac{\sqrt{3}}{2}-i\frac{1}{2}$ ។

លំហាត់ទី១៩

គណនាឫសទី n នៃចំនួនកុំផ្លិច $Z=i$

ចំពោះ $n=2\,,\ 3\ ,4\ ,5\ ,6$ ។

ដំណោះស្រាយ

គណនាឫសទី n នៃចំនួនកុំផ្លិច $Z=i$

ចំពោះ $n=2\,,\ 3\ ,4\ ,5\ ,6$

យើងមាន: $Z=i=\cos(\frac{\pi}{2}+2k\pi)+i.\sin(\frac{\pi}{2}+2k\pi)$

តាង W_k ជាឫសទី n នៃ $Z=i=\cos(\frac{\pi}{2}+2k\pi)+i.\sin(\frac{\pi}{2}+2k\pi)$

តាមរូបមន្តគេបាន $W_k=\cos\frac{(1+4k)\pi}{2n}+i.\sin\frac{(1+4k)\pi}{2n}$

ក. ចំពោះ $n=2$ គេបាន $W_k=\cos\frac{(1+4k)\pi}{4}+i.\sin\frac{(1+4k)\pi}{4}$

-បើ $k=0:\ W_0=\cos\frac{\pi}{4}+i.\sin\frac{\pi}{4}=\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}$

-បើ $k=1:\ W_1=\cos\frac{5\pi}{4}+i.\sin\frac{5\pi}{4}=-\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}$

ខ. ចំពោះ $n=3$

គេបាន $W_k=\cos\frac{(4k+1)\pi}{6}+i.\sin\frac{(4k+1)\pi}{6}$

-បើ $k=0:\ W_0=\cos\frac{\pi}{6}+i.\sin\frac{\pi}{6}=.\frac{\sqrt{3}}{2}+i\frac{1}{2}$

-បើ $k=1:W_1=\cos\frac{5\pi}{6}+i.\sin\frac{5\pi}{6}=-\frac{\sqrt{3}}{2}+i\frac{1}{2}$

-បើ $k=2 : W_2=\cos\frac{3\pi}{2}+i\sin\frac{3\pi}{2}=-i$

គ. ចំពោះ $n=4$ គេបាន $W_k=\cos\frac{(4k+1)\pi}{8}+i.\sin\frac{(4k+1)\pi}{8}$

-បើ $k=0 : W_0=\cos\frac{\pi}{8}+i.\sin\frac{\pi}{8}$

-បើ $k=1 : W_1=\cos\frac{5\pi}{8}+i.\sin\frac{5\pi}{8}$

-បើ $k=2 : W_2=\cos\frac{9\pi}{8}+i.\sin\frac{9\pi}{8}$

-បើ $k=3 : W_3=\cos\frac{13\pi}{8}+i.\sin\frac{13\pi}{8}$

ឃ. ចំពោះ $n=5$ គេបាន $W_k=\cos\frac{(1+4k)\pi}{10}+i.\sin\frac{(1+4k)\pi}{10}$

-បើ $k=0 \quad W_0=\cos\frac{\pi}{10}+i.\sin\frac{\pi}{10}$

-បើ $k=1 \quad W_1=\cos\frac{\pi}{2}+i.\sin\frac{\pi}{2}=i$

-បើ $k=2 \quad W_2=\cos\frac{9}{10}\pi+i.\sin\frac{9}{10}\pi$

-បើ $k=3 \quad W_3=\cos\frac{13\pi}{10}+i.\sin\frac{13\pi}{10}$

-បើ $k=4 \quad W_4=\cos\frac{17\pi}{10}+i.\sin\frac{17\pi}{10}$

ង. ចំពោះ $n=6$ គេបាន $W_k=\cos\frac{(1+4k)\pi}{12}+i.\sin\frac{(1+4k)\pi}{12}$

-បើ $k=0 \quad W_0=\cos\frac{\pi}{12}+i\sin\frac{\pi}{12}$

-បើ $k=1 \quad W_1=\cos\frac{5\pi}{12}+i.\sin\frac{5\pi}{12}$

-បើ $k=2 \quad W_2=\cos\frac{3\pi}{4}+i\sin\frac{3\pi}{4}=-\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}$

-បើ $k=3 \quad W_3=\cos\frac{13\pi}{12}+i.\sin\frac{13\pi}{12}$

-បើ $k=4$ $\quad W_4=\cos\frac{17\pi}{12}+i.\sin\frac{17\pi}{12}$

-បើ $k=5$ $\quad W_5=\cos\frac{7\pi}{4}+i.\sin\frac{7\pi}{4}=-\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}$ ។

✍✍✍✍✍

លំហាត់អនុវត្តន៍

1. ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ពីជគណិត $Z=a+i.b$ ៖

ក. $a/Z=(2-5i)(3+i)$ $\quad$ $b/Z=(1+i)(1-2i)(1+3i)$

ខ. $a/Z=(2+3i)^2+(1+2i)^2$ $\quad$ $b/Z=(3-2i)^2+(1-2i)^2$

គ. $a/Z=(1+2i)^3+(1+i)^3$ $\quad$ $b/Z=(1-2i)^3+(2-i)^3$

ឃ. $a/Z=\dfrac{4+7i}{2+i}$ $\quad$ $b/Z=\dfrac{9+7i}{3-2i}$

ង. $a/Z=\dfrac{1+2i}{(2+i)(2-\sqrt{3}i)}$ $\quad$ $b/Z=\left(\dfrac{1-\sqrt{2}-i}{1+\sqrt{2}+i}\right)^2$

2. ចូរកំនត់ពីរចំនួនពិត a និង b ដើម្បីឱ្យចំនួនកុំផ្លិច $z=2+3i$ ជាឬសមួយរបស់សមីការ (E): $z^2+az+b=0$ ។

3. ចូរកំនត់ពីរចំនួនពិត a និង b ដើម្បីឱ្យចំនួនកុំផ្លិច $z=1+2i$ ជាឬសមួយរបស់សមីការ (E): $z^3+az+b=0$ ។

4. គេមានសមីការ (E): $z^2-3z+4+6i=0$

ក-កំនត់ចំនួនពិត b ដើម្បីឱ្យ $z_0=b.i$ ជាឬសរបស់សមីការ (E) ។

ខ-ចូរដោះស្រាយសមីការ (E) ក្នុងសំណុំកុំផ្លិច ។

5. គេមានសមីការ (E): $z^2-5(1+i)z-3(4-3i)=0$

ក-ចូរផ្ទៀងផ្ទាត់ថា $48+14i=(7+i)^2$

ខ-ចូរដោះស្រាយសមីការ (E) ក្នុងសំណុំកុំផ្លិច ។

6. គេមានសមីការ $(E): z^2-(a+i.b)z+a-3+5i=0$ ដែល $a,b\in IR$ ។

កំនត់តម្លៃ a និង b ដើម្បីឱ្យ $z_1=3+2i$ ជាឬសមួយរបស់សមីការ (E)

រួចចូរកំនត់រកឬស z_2 មួយទៀតចំពោះតម្លៃ a និង b ដែលបានរកឃើញ ។

7. គេមានសមីការ $(E): z^3-(5+i)z^2+(10+9i)z-2(1+8i)=0$ ។

ក-កំនត់ចំនួនពិត b ដើម្បីឱ្យ $z_0=b.i$ ជាឬសរបស់សមីការ (E) ។

ខ-ចូរសរសេរសមីការ (E) ជារាង $(z-z_0)(z^2+pz+q)=0$ ដែល p និង q

ជាចំនួនកុំផ្លិចពីរដែលគេត្រូវរក ។

គ-ចូរផ្ទៀងផ្ទាត់ថា $-8+6i=(1+3i)^2$

រួចដោះស្រាយ សមីការ(E) ក្នុងសំណុំកុំផ្លិច ។

8. ចូរដោះស្រាយសមីការខាងក្រោមក្នុងសំណុំកុំផ្លិច ៖

a/ $iz^2+(2-3i)z-(1-5i)=0$

b/ $(2-i)z^2-5(1+i)z-2(3+4i)=0$

c/ $(1+i)z^2-(1+7i)z-2(2-3i)=0$

9. ចូរបង្កើតសមីការដឺក្រេទីពីរដែលមាន α និង β ជាឬសក្នុងករណីនីមួយៗ

ខាងក្រោម ៖

ក. a/ $\alpha=2+11i$, $\beta=2-11i$ b/ $\alpha=-2-3i$, $\beta=-2+3i$

ខ. a/ $\alpha=3+2i$, $\beta=1-3i$ b/ $\alpha=2+3i$, $\beta=3-2i$

គ. a/ $\alpha=-1+2i$, $\beta=3-2i$ b/ $\alpha=-\sqrt{3}-i$, $\beta=1+i\sqrt{3}$

10. គេមានចំនួនកុំផ្លិច $\alpha=1+3i$ និង $\beta=1-2i$ ។

ចូរសរសេរសមីការដឺក្រេទីពីរមួយដែលមាន $Z_1=\alpha^2+\beta^2$

និង $Z_2 = \alpha^2.\beta^2$ ជាឫស.

11. ចូរកំនត់រកចំនួនកុំផ្លិចដែលមានម៉ូឌុលស្មើ 8 ហើយការេរបស់វា ជាចំនួននិម្មិតសុទ្ធ។

12. ចូរកំនត់ពីរចំនួនពិត x និង y បើគេដឹងថា :

$$(1+i)(x+iy)+(3-2i)(x-iy)=\frac{8-9i}{1+2i}$$ ។

13. ចូរកំនត់ពីរចំនួនពិត x និង y បើគេដឹងថា :

$$(3+2i)(x+y)+(1-2i)(x-y)=\frac{5-13i}{1-i}$$ ។

14. គេមានសមីការ $(E): \; az^2+bz+c=0 \; , a\neq 0 \, , a,b,c\in IR$ ។

ចូរបង្ហាញថាបើ z_0 ជាឫសសមីការ (E) នោះ $\bar{z}_0$ ក៏ជាឫសរបស់ (E) ដែរ ។

15. គេមានចំនួនកុំផ្លិច $\alpha=\frac{1+i\sqrt{5}}{2}$ និង $\beta=\frac{1-i\sqrt{5}}{2}$ ។

ក-ចូរបង្កើតសមីការដឺក្រេទីពីរមួយដែលមាន α និង β ជាឫស ។

ខ-គេតាង $S_n=\alpha^n+\beta^n$ ចំពោះគ្រប់ $n\in IN$ ។

ចូរស្រាយបញ្ជាក់ទំនាក់ទំនង $S_{n+2}-S_{n+1}+\frac{3}{2}S_n=0$?

គ-ដោយមិនបាច់ពន្លាតចូរគណនា $N=\left(\frac{1+i\sqrt{5}}{2}\right)^{10}+\left(\frac{1-i\sqrt{5}}{2}\right)^{10}$ ។

16. គេមានសមីការ $(E)\; : z^2-(\alpha+\beta)iz-\alpha\beta=0 \; , \; \alpha,\beta\in IR^*$

ចូរបង្ហាញថាសមីការ (E) ឫសពីរសុទ្ធតែជាចំនួននិម្មិតសុទ្ធដែលគេនឹងបញ្ជាក់

17. គេមានសមីការដឺក្រេទីពីរ $(E): \; Az^2+Bz+C=0$

ដែល $A\neq 0$ ហើយ A,B,C ជាចំនួនកុំផ្លិច ។

ក. បង្ហាញថាបើ $A-C=i.B$ នោះសមីការ (E) មានឫសពីរកំនត់ដោយ :

$z_1=i\ ,\ z_2=-i.\dfrac{C}{A}$ ។

ខ. បង្ហាញថាបើ $A-C=-i.B$ នោះសមីការ (E) មានឫសពីរកំនត់ដោយ :

$z_1=-i\ ,\ z_2=i.\dfrac{C}{A}$ ។

គ. អនុវត្តន៏ : ចូរដោះស្រាយសមីការខាងក្រោមក្នុងសំណុំកុំផ្លិច :

a/ $(1+i)z^2-(2+3i)z-2+3i=0$

b/ $(1-2i)z^2+(1+2i)z-(1+i)=0$

18. គេឱ្យចំនួនកុំផ្លិច $Z_1=1+2i$ និង $Z_2=3-i$ ។

ចូរកំនត់រកផ្នែកពិត និងផ្នែកនិម្មិតនៃចំនួនកុំផ្លិច W

បើគេដឹងថា $\dfrac{1}{W}=\dfrac{1}{Z_1}+\dfrac{1}{Z_2}$ ។

19. គេមានចំនួនកុំផ្លិច α និង β ដែល $\alpha+\beta=3-2i$ និង $\alpha.\beta=5(1-i)$ ។

ចូរកំនត់ផ្នែកពិត និង ផ្នែកនិម្មិតនៃ $Z=\dfrac{1}{\alpha^2}+\dfrac{1}{\beta^2}$ ។

20. គេមានសមីការ $(E): i.Z^2-(2+3i)Z+5(1+i)=0$

ក. កំនត់ចំនួនពិត a ដើម្បីឱ្យ $Z_1=a+i$ ជាឫសមួយរបស់សមីការ (E)

រួចគណនាឫស Z_2 មួយទៀតរបស់សមីការ ។

ខ. ចូរកំនត់ចំនួនពិត p និង q ដើម្បីឱ្យ $\dfrac{p}{Z_1}+\dfrac{q}{Z_2}=\dfrac{p+q-2}{Z_1+Z_2}$ ។

21. គេមានចំនួនកុំផ្លិចពីរ Z_1 និង Z_2 ដែល $Z_1+Z_2=3+i$ និង $Z_1.Z_2=4+3i$

ក. ចូរបង្ហាញថា $(Z_1)^2+(Z_2)^2=0$ ។

ខ. ចូរកំនត់រកផ្នែកពិត និង ផ្នែកនិម្មិត នៃ $Z=Z_1^4+Z_2^4$ ។

គ. ចូរផ្ទៀងផ្ទាត់ថា $(Z_1+Z_2)^2-4Z_1.Z_2=-(Z_1+Z_2)^2$ រួចកំនត់រក Z_1 និង Z_2 ។

22. គេមានចំនួនកុំផ្លិច $Z_1=x^2+ixy$ និង $Z_2=y^2-ixy$ ដែល $x,y\in IR$ ។

ចូរកំនត់ x និង y ដើម្បីឱ្យ $Z_1-Z_2=(\sqrt{2006}+i\sqrt{2007})^2$ ។

23. គេឱ្យចំនួនកុំផ្លិច ៖

$Z_1=(a-b)+i(b-c)$, $Z_2=(b-c)+i(c-a)$ និង $Z_2=(c-a)+i(a-b)$

ដែល a , b , c ជាបីចំនួនពិតខុសគ្នា ។

ចូរបង្ហាញថា $Z_1^{\ 3}+Z_2^{\ 3}+Z_3^{\ 3}=3Z_1.Z_2.Z_3$

24. ចូរគណនាឬសការេនៃចំនួនកុំផ្លិចខាងក្រោម ៖

ក. a/ $Z=48+14i$ b/ $Z=-24-10i$

ខ. a/ $Z=-40+42i$ b/ $Z=77-36i$

គ. a/ $Z=55-48i$ b/ $Z=1+i\sqrt{6}$

25. ចូរសរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ត្រីកោណមាត្រ ៖

ក. a/ $Z=1+i\sqrt{3}$ b/ $Z=-2\sqrt{3}+2i$

ខ. a/ $Z=\frac{1-i}{\sqrt{2}}$ b/ $Z=-\sqrt{3}-3i$

គ. a/ $Z=\frac{\sqrt{6}-i\sqrt{2}}{2}$ b/ $Z=2+2i$

ឃ. a/ $Z=-1-\frac{i}{\sqrt{3}}$ b/ $Z=-\sqrt{2}+i\sqrt{2}$

ង. a/ $Z=1+\sqrt{2}+i$ b/ $Z=2-\sqrt{3}+i$

26. ចូរសរសេរជាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិចខាងក្រោម ៖

ក. $a / Z=1+\cos\frac{4\pi}{9}+i.\sin\frac{4\pi}{9}$ $\qquad$ $b / Z=1+\sin\frac{\pi}{10}+i.\cos\frac{\pi}{10}$

ខ. $a / Z=\sin\frac{2\pi}{7}+i(1-\cos\frac{2\pi}{7})$ $\qquad$ $b / Z=1-\cos\frac{4\pi}{5}-i\sin\frac{4\pi}{5}$

គ. $a / Z=\sqrt{2-2\cos\frac{\pi}{5}}+i.\sqrt{2+2\cos\frac{\pi}{5}}$ $\qquad$ $b / Z=1+i\tan\frac{\pi}{7}$

ឃ. $a / Z=-\sin\frac{\pi}{10}-i.\cos\frac{\pi}{10}$ $\qquad$ $b / Z=(\sqrt{3}-2)(\cos\frac{\pi}{8}+i\sin\frac{\pi}{8})$

ង. $Z=\sqrt{2+\sqrt{2+\sqrt{2+2\cos\frac{\pi}{4}}}}+i.\sqrt{2-\sqrt{2+\sqrt{2+2\cos\frac{\pi}{4}}}}$ ។

27. ចូរដោះស្រាយសមីការខាងក្រោមរួចសរសេរឫសនីមួយៗ

ជារាងត្រីកោណមាត្រ ៖

ក. $a / z^{2}-2z+4=0$ $\qquad$ $b / 2z^{2}-2z+1=0$

ខ. $a / z^{2}+\sqrt{3}.z+1=0$ $\qquad$ $b / z^{2}+z+1=0$

28. ចូរសរសេរ $Z=\sqrt{2+\sqrt{3}}+i.\sqrt{2-\sqrt{3}}$ ជារាងត្រីកោណមាត្រ ។

29. ចូរសរសេរ $Z=\sqrt{2-\sqrt{2}}+i\sqrt{2+\sqrt{2}}$ ជារាងត្រីកោណមាត្រ ។

30. ក-គណនាតម្លៃប្រាកដនៃ $\sin\frac{\pi}{10}, \cos\frac{\pi}{10}$ និង $\tan\frac{\pi}{10}$ ។

ខ-ទាញរកទម្រង់ត្រីកោណមាត្រនៃ $Z=1+i.\sqrt{5-2\sqrt{2}}$ ។

31. គេឱ្យចំនួនកុំផ្លិច $z_{1}=\frac{\sqrt{2}+i\sqrt{6}}{2}$ និង $z_{2}=1+i$

ក. ចូរសរសេរ $Z=\frac{z_{1}}{z_{2}}$ ជាទម្រង់ $a+b.i$ ។

ខ. ចូរសរសេរ z_{1}, z_{2} និង $Z=\frac{z_{1}}{z_{2}}$ ជាទម្រង់ត្រីកោណមាត្រ ។

គ. ដោយប្រើលទ្ធផលខាងលើចូរទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$ ។

32. គេមានចំនួនកុំផ្លិច $z_1=\frac{1+i}{\sqrt{2}}$ និង $z_2=2\sqrt{3}+2i$ ។

ក. ចូរសរសេរ $Z=z_1.z_2$ ជាទម្រង់ពីជគណិត ។

ខ. ចូរសរសេរ z_1 , z_2 និង $Z=z_1.z_2$ ជាទម្រង់ត្រីកោណមាត្រ ។

គ. ដោយប្រើលទ្ធផលខាងលើចូរទាញរកតម្លៃប្រាកដនៃ $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$ ។

33. គេឱ្យ $z=-1-i$ ។ ចូរសរសេរ z និង z^{2007} ជាទម្រង់ត្រីកោណមាត្រ ។

34. គេឱ្យ $z=-\sqrt{3}+i$ ។ ចូរសរសេរ z និង z^{2007} ជាទម្រង់ត្រីកោណមាត្រ ។

35. គេឱ្យ $z=\frac{1}{2}+\frac{i\sqrt{3}}{2}$ ។ ចូរសរសេរ z និង z^{2007} ជាទម្រង់ត្រីកោណមាត្រ ។

36. គេឱ្យចំនួនកុំផ្លិច $Z=2+\sqrt{3}+i$

ក-ចូរផ្ទៀងផ្ទាត់ថាម៉ូឌុល $|Z|=\sqrt{6}+\sqrt{2}$ ។

ខ-បង្ហាញថា $Z=2(1+\cos\frac{\pi}{6}+i.\sin\frac{\pi}{6})$ រួចទាញរកទម្រង់ត្រីកោណមាត្រនៃ Z ។

គ-ទាញបង្ហាញថា $\cos\frac{\pi}{12}=\frac{\sqrt{6}+\sqrt{2}}{4}$ ។

37. គេឱ្យចំនួនកុំផ្លិច $Z=\sqrt{2}+1+i$

ក-ចូរផ្ទៀងផ្ទាត់ថាម៉ូឌុល $|Z|=\sqrt{2}.\sqrt{2+\sqrt{2}}$ ។

ខ-បង្ហាញថា $Z=\sqrt{2}(1+\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$ រួចទាញទម្រង់ត្រីកោណមាត្រនៃ Z

គ-ទាញបង្ហាញថា $\cos\frac{\pi}{8}=\frac{\sqrt{2+\sqrt{2}}}{2}$ ។

38. គេមានចំនួនកុំផ្លិច ៖

$$Z_1 = \frac{\sqrt{3}+i}{2} \text{ និង } Z_2 = (\sqrt{3}+1)+i(\sqrt{3}-1) \text{ ។}$$

ក. ចូរសរសេរ $U = Z_1.Z_2$ ជារាងពីជគណិត ។

ខ. ចូរសរសេរ U និង Z_1 ជារាងត្រីកោណមាត្រ រួចទាញរកម៉ូឌុល

និងអាគុយម៉ង់នៃចំនួនកុំផ្លិច Z_2 ។

គ.ចូរទាញបង្ហាញថា $\cos\frac{\pi}{12} = \frac{\sqrt{6}+\sqrt{2}}{4}$ និង $\sin\frac{\pi}{12} = \frac{\sqrt{6}-\sqrt{2}}{4}$ ។

39. គេឱ្យចំនួនកុំផ្លិច $z = \frac{1+i\sqrt{3}}{2}$ ។

ចូររកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $U = \frac{z^{2007}}{1+z^2}$ ។

40. គេឱ្យចំនួនកុំផ្លិច $Z_n = \frac{n^2+n-1-i(2n+1)}{(n^2+n-1)^2+(2n+1)^2}$

ដែល n ជាចំនួនគត់ធម្មជាតិ ។

ក. បង្ហាញថា $Z_n = \frac{1}{n+i} - \frac{1}{n+1+i}$ ។

ខ. គណនា $S_n = Z_0 + Z_1 + Z_2 + ... + Z_n$ ដោយសរសេរ

លទ្ធផលដែលបានជារាងពីជគណិត ។

41. គមានស្វ៊ីតនៃចំនួនកុំផ្លិច (Z_n) កំនត់ដោយ ៖

$$Z_0 = \frac{3+i\sqrt{3}}{2} \text{ និង } Z_{n+1} = \frac{1+i\sqrt{3}}{2}Z_n - \frac{1-i\sqrt{3}}{2}$$

ដែល $n \in IN$ ។

ក. គេតាង $U_n = Z_n - 1$ ចំពោះគ្រប់ $n \in IN$ ។

ចូរបង្ហាញថា $U_{n+1}=\dfrac{1+i\sqrt{3}}{2}.U_n \ , \forall n\in IN$

ខ. ចូរសរសេរ U_n ជាទម្រង់ត្រីកោណមាត្រ ។

គ. ចូរស្រាយបញ្ជាក់ថា :

$$Z_n=2\cos\frac{(n+1)\pi}{6}\left[\cos\frac{(n+1)\pi}{6}+i.\sin\frac{(n+1)\pi}{6}\right]$$

ឃ. ចូរកំនត់ទម្រង់ត្រីកោណមាត្រនៃ Z_n ។

42. បើ z ជាចំនួនកុំផ្លិចដែលផ្ទៀងផ្ទាត់ទំនាក់ទំនង :

$z^{2n}=(1+z)^n$ ចំពោះគ្រប់ $n\in IN$ នោះចូរស្រាយបញ្ជាក់

ថាចំនួនកុំផ្លិច z និង $1+\dfrac{1}{z}$ មានម៉ូឌុលស្មើគ្នា ។

43. ដោះស្រាយសមីការ $z^3+\overline{z}^3+i|z|^2=1+i$ ។

44. គេមានចំនួនកុំផ្លិច $\alpha=\dfrac{1+i\sqrt{7}}{2}$ និង $\beta=\dfrac{1-i\sqrt{7}}{2}$

ក. សរសេរសមីការដឺក្រេទីពីរដែលមាន $\alpha\ ,\beta$ ជាឬស ។

ខ. តាង $\forall n\in Z: S_n=\alpha^n+\beta^n$ ។

ចូរស្រាយថា $S_{n+2}-S_{n+1}+2S_n=0$?

45. គេឱ្យចំនួនកុំផ្លិច : $\begin{cases} Z_1=a_1+i.b_1 \\ Z_2=a_2+i.b_2 \\ Z_3=a_3+i.b_3 \end{cases}$

ដែល a_1,a_2,a_3,b_1,b_2,b_3 ជាចំនួនពិត ។

ក្នុងលំហប្រកបដោយតំរុយអរតូនរម៉ាល់ $(o,\vec{i},\vec{j},\vec{k})$

គេឱ្យត្រីកោណ ABC មួយដែល $\overrightarrow{AB}(a_1, a_2, a_3)$ និង $\overrightarrow{AC}(b_1, b_2, b_3)$ ។

ក.ចូរកំនត់ប្រភេទនៃត្រីកោណ ABC កាលណាគេមាន

ទំនាក់ទំនង $Z_1^2 + Z_2^2 + Z_3^2 = 0$ ។

ខ. ចូរស្រាយថាបើ ABC ជាត្រីកោណកែងសមបាទកំពូលA

នោះគេបាន $(Z_1.Z_2.Z_3)^2 = \dfrac{Z_1^6 + Z_2^6 + Z_3^6}{3}$ ។

46. គេឱ្យចំនួនពិត x ដែល $x \neq \dfrac{\pi}{2} + k\pi \, , k \in Z$

ក. ចូរស្រាយបញ្ជាក់ថា ៖

$$1 - 3\tan^2 x + i.(3\tan x - \tan^3 x) = \frac{\cos 3x + i\sin 3x}{\cos^3 x}$$

ខ.ប្រើទំនាក់ទំនងខាងលើចូរទាញបង្ហាញថា ៖

$$\tan 3x = \frac{3\tan x - \tan^3 x}{1 - 3\tan^2 x}$$

គ. ចូរសរសេរ $\tan(\dfrac{\pi}{3} - x)$ និង $\tan(\dfrac{\pi}{3} + x)$ ជាអនុគមន៍

នៃ $\tan x$ ។

ឃ. ទាញឱ្យបានថា $\tan(\dfrac{\pi}{3} - x)\tan(\dfrac{\pi}{3} + x) = \dfrac{\tan 3x}{\tan x}$ ។

ង.ចូរគណនាផលគុណ $P_n = \prod_{k=0}^{n} [\tan(\dfrac{\pi}{3} - 3^n a).\tan(\dfrac{\pi}{3} + 3^n a)]$ ។

47-ដោះស្រាយសមីការ $|z| - i.z = 1 - 3i$ ដែល z ជាចំនួនកុំផ្លិច ។

48-ដោះស្រាយសមីការ $\log_5(z.\bar{z}) + z = 3\,(1 + 2i)$ ។

49-ដោះស្រាយសមីការ $|z-1+i|+iz=22+4i$ ។

50-គេឱ្យស្វ៊ីតនៃចំនួនកុំផ្លិច (Z_n) កំនត់ដោយ ៖

$Z_0=1$ និង $Z_{n+1}=\frac{1}{2}(Z_n+|Z_n|)$ ដែល $n\in IN$

គណនា Z_n ដោយសរសេរលទ្ធផលក្រោមទម្រង់ត្រីកោណមាត្រ ។

✍✍✍✍✍

មេរៀនទី២

លីមីតនៃអនុគមន៍

១_និយមន័យ

អនុគមន៍ $f(x)$ មានលីមីតស្មើ L កាលណា x ខិតជិត x_0 មានន័យថាចំពោះគ្រប់ចំនួន $\varepsilon>0$ គេមានចំនួន $\alpha>0$ ដែល $0<|x-x_0|<\alpha$ គេបាន $|f(x)-L|<\varepsilon$ ។

គេកំនត់សរសេរ ៖ $\lim\limits_{x\to x_0} f(x)=L$ ។

២_ទ្រឹស្តីបទលីមីត

$1/\ \lim\limits_{x\to x_0}[f(x)+g(x)]=\lim\limits_{x\to x_0} f(x)+\lim\limits_{x\to x_0} g(x)$

$2/\ \lim\limits_{x\to x_0}[k.f(x)]=k\lim\limits_{x\to x_0} f(x)\ ;\ k\in IR$

$3/\ \lim\limits_{x\to x_0}[f(x).g(x)]=\lim\limits_{x\to x_0} f(x)\times\lim\limits_{x\to x_0} g(x)$

$4/\ \lim\limits_{x\to x_0}\left[\dfrac{f(x)}{g(x)}\right]=\dfrac{\lim\limits_{x\to x_0} f(x)}{\lim\limits_{x\to x_0} g(x)}\ ;\ \lim\limits_{x\to x_0} g(x)\neq 0$

$5/\ \lim\limits_{x\to x_0}[f(x)]^n=\left[\lim\limits_{x\to x_0} f(x)\right]^n\ ;\ n\in IN^*$

៣_ទ្រឹស្តីបទលីមីតអនុគមន៍ត្រីកោណមាត្រ

$1/\ \lim\limits_{x\to 0}\dfrac{\sin x}{x}=\lim\limits_{x\to 0}\dfrac{x}{\sin x}=1$

$2/\ \lim\limits_{x\to 0}\dfrac{\tan x}{x}=\lim\limits_{x\to 0}\dfrac{x}{\tan x}=1$

៤_លីមីតឆ្វេង_ស្តាំ

បើគេមាន $\lim\limits_{x\to x_0^-} f(x)=L$ & $\lim\limits_{x\to x_0^+} f(x)=L$ នោះ $\lim\limits_{x\to x_0} f(x)=L$

ដែល $\lim\limits_{x\to x_0^-} f(x)$ & $\lim\limits_{x\to x_0^+} f(x)$ តាងរៀងគ្នាជាលីមីតឆ្វេងនិងស្តាំ

៥_ភាពជាប់នៃអនុគមន៍

ក_ភាពជាប់ត្រង់ចំនុចមួយ

អនុគមន៍ $y=f(x)$ ជាប់ត្រង់ចំនុច $x=x_0$ លុះត្រាតែ

f បំពេញល័ក្ខខ័ណ្ឌបីដូចខាងក្រោម ៖

១, $f(x_0)$ មានន័យលីមីត ($f(a)$ ជាចំនួនពិត)

២, $\lim\limits_{x\to x_0} f(x)$ មាន (លីមីតជាចំនួនពិត)

៣, $\lim\limits_{x\to x_0} f(x)=f(x_0)$

(លីមីតស្មើនឹងតម្លៃនៃអនុគមន៍ត្រង់ចំនុច x_0)

ខ_ភាពជាប់លើចន្លោះមួយ

_អនុគមន៍ $f(x)$ លើចន្លោះបើក $]a;b[$ លុះត្រាតែ

$f(x)$ ជាប់ចំពោះគ្រប់ចំនួននៅក្នុងចន្លោះបើកនោះ ។

_អនុគមន៍ $f(x)$ លើចន្លោះបើក $[a\,;b]$ លុះត្រាតែ $f(x)$

ជាប់លើ $]a;b[$ និងមាន $\lim\limits_{x\to a^+} f(x)=f(a)$; $\lim\limits_{x\to b^-} f(x)=f(b)$ ។

៦_ទ្រឹស្តីបទតម្លៃកណ្តាល

បើអនុគមន៍ $f(x)$ ជាប់លើចន្លោះ $[a; b]$

ហើយ $f(a).f(b) < 0$ នោះយ៉ាងហោចណាស់មានចំនួន x_0

មួយនៅចន្លោះ a និង b ដែល $f(x_0) = 0$ ។



៧_លីមីតត្រង់អនន្ត

បើ $f(x)$ ជាអនុគមន៍មួយ និង L ជាចំនួនពិត

. $\lim\limits_{x \to +\infty} f(x) = L$ មានន័យថាចំពោះគ្រប់ $\varepsilon > 0$ គេមានចំនួន

$M > 0$ ដែល $|f(x) - L| < \varepsilon$ កាលណា $x > M$ ។

. $\lim\limits_{x \to -\infty} f(x) = L$ មានន័យថាចំពោះគ្រប់ $\varepsilon > 0$ គេមានចំនួន

$N < 0$ ដែល $|f(x) - L| < \varepsilon$ កាលណា $x < N$ ។

៨_ លក្ខណះលីមីតត្រង់អនន្ត

$1/ \lim_{x\to+\infty}[k\, f(x)] = k \lim_{x\to+\infty} f(x)$; $2/ \lim_{x\to+\infty}[f(x)+g(x)] = \lim_{x\to+\infty} f(x) + \lim_{x\to+\infty} g(x)$

$3/ \lim_{x\to+\infty}[f(x)-g(x)] = \lim_{x\to-\infty} f(x) - \lim_{x\to-\infty} g(x)$

$4/ \lim_{x\to+\infty}[f(x).g(x)] = \lim_{x\to+\infty} f(x) \times \lim_{x\to+\infty} g(x)$

$5/ \lim_{x\to+\infty}\left[\frac{f(x)}{g(x)}\right] = \frac{\lim_{x\to+\infty} f(x)}{\lim_{x\to+\infty} g(x)}$; $\lim_{x\to+\infty} g(x) \neq 0$

(លក្ខណះលីមីតត្រង់ $-\infty$ ដូចគ្នានឹងលីមីតត្រង់ $+\infty$ ដែរ)

៩_អាស៊ីមតូតនៃខ្សែកោង

ក, អាស៊ីមតូតឈរ

អនុគមន៍ $y=f(x)$ បើ $\lim_{x\to a} f(x) = +\infty$ ឬ $\lim_{x\to a} f(x) = -\infty$

នោះគេថាបន្ទាត់មានសមីការ $x=a$ ជាអាស៊ីមតូតឈរ

នៃក្រាបតាង $f(x)$ ។



ខ, អាស៊ីមតូតដេក

អនុគមន៍ $y=f(x)$ បើ $\lim_{x\to+\infty} f(x) = b$ ឬ $\lim_{x\to-\infty} f(x) = b$

នោះគេថាបន្ទាត់មានសមីការ $y=b$ ជាអាស៊ីមតូតដេក

នៃក្រាបតាង $f(x)$ ។



គ, អាស៊ីមតូតទ្រេត

អនុគមន៍ $y=f(x)$ បើគេអាចសរសេរ $f(x)=ax+b+g(x)$ ដែលលីមីត $\lim_{x\to\pm\infty} g(x)=0$ នោះគេថាបន្ទាត់មានសមីការ $y=ax+b$ ជាអាស៊ីមតូតទ្រេតនៃក្រាបតាង $f(x)$ ។



លំហាត់ទី១

ចូរគណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 1}\dfrac{x+x^2+x^3-3}{x-1}$

ខ. $\lim\limits_{x\to 1}\dfrac{x+x^2+x^3+.......+x^n-3}{x-1}$, $n\in IN^*$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 1}\dfrac{x+x^2+x^3-3}{x-1}$

$$=\lim_{x\to 1}\frac{(x-1)+(x^2-1)+(x^3-1)}{x-1}$$

$$=\lim_{x\to 1}\frac{(x-1)+(x-1)(x+1)+(x-1)(x^2+x+1)}{(x-1)}$$

$$=\lim_{x\to 1}\left[1+(x+1)+(x^2+x+1)\right]=1+2+3=6$$

ដូចនេះ . $\boxed{\lim\limits_{x\to 1}\dfrac{x+x^2+x^3-3}{x-1}=6}$ ។

ខ. $\lim\limits_{x\to 1}\dfrac{x+x^2+x^3+.......+x^n-3}{x-1}$, $n\in IN^*$

$$=\lim_{x\to 1}\frac{(x-1)+(x^2-1)+(x^3-1)+.....+(x^n-1)}{x-1}$$

$$=\lim_{x\to 1}\frac{(x-1)+(x-1)(x+1)+(x-1)(x^2+x+1)+...+(x-1)(x^{n-1}+...+x+1)}{x-1}$$

$$=\lim_{x\to 1}\left[1+(x+1)+(x^2+x+1)+...+(x^{n-1}+...+x+1)\right]$$

$$=1+2+3+.......+n=\frac{n(n+1)}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{x+x^2+x^3+......+x^n-n}{x-1}=\dfrac{n(n+1)}{2}}$ ។

លំហាត់ទី២

ចូរគណនាលីមីតខាងក្រោម :

ក. $\lim_{x\to 1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)$

ខ. $\lim_{x\to 1}(\frac{1}{1-x}-\frac{n}{1-x^n})$, $n\in IN^*$

គ. $\lim_{x\to 1}\left(\frac{m}{1-x^m}-\frac{n}{1-x^n}\right)$, $m,n\in IN^*$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម :

ក. $\lim_{x\to 1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)$

$$=\lim_{x\to 1}\left[\frac{1}{1-x}-\frac{3}{(1-x)(1+x+x^2)}\right]$$

$$=\lim_{x\to 1}\left[\frac{(1+x+x^2)-3}{(1-x)(1+x+x^2)}\right]$$

$$=\lim_{x\to 1}\frac{(x-1)+(x^2-1)}{(1-x)(1+x+x^2)}=\lim_{x\to 1}\frac{(x-1)+(x-1)(x+1)}{-(x-1)(x^2+x+1)}$$

$$=\lim_{x\to 1}\frac{1+(x+1)}{-(x^2+x+1)}=\frac{1+2}{-3}=-1$$

ដូចនេះ $\boxed{\lim_{x\to 1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)=-1}$ ។

ខ. $\lim_{x\to 1}(\frac{1}{1-x}-\frac{n}{1-x^n})$, $n\in IN^*$

$$= \lim_{x\to1}\left[\frac{1}{1-x} - \frac{n}{(1-x)(1+x+...+x^{n-1})}\right]$$

$$= \lim_{x\to1}\frac{(1+x+...+x^{n-1})-n}{(1-x)(1+x+....+x^{n-1})}$$

$$= \lim_{x\to1}\frac{(x-1)+....+(x^{n-1}-1)}{-(x-1)(1+x+...+x^{n-1})}$$

$$= \lim_{x\to1}\frac{(x-1)+......+(x-1)(x^{n-2}+....+x+1)}{-(x-1)(1+x+.....+x^{n-1})}$$

$$= \lim_{x\to1}\frac{1+.....+(x^{n-2}+....+x+1)}{-(1+x+.....+x^{n-1})} = \frac{1+2+.....+(n-1)}{-n} = -\frac{n-1}{2}$$

ដូចនេះ $\boxed{\lim_{x\to1}\left(\frac{1}{1-x} - \frac{n}{1-x^n}\right) = -\frac{n-1}{2}}$ ។

គ. $\lim_{x\to1}\left(\frac{m}{1-x^m} - \frac{n}{1-x^n}\right)$, $m, n \in IN*$

$$= \lim_{x\to1}\left(\frac{1}{1-x} - \frac{n}{1-x^2} - \frac{1}{1-x} + \frac{m}{1-x^m}\right)$$

$$= \lim_{x\to1}\left[\left(\frac{1}{1-x} - \frac{n}{1-x^n}\right) - \left(\frac{1}{1-x} - \frac{m}{1-x^m}\right)\right]$$

$$= \lim_{x\to1}\left(\frac{1}{1-x} - \frac{n}{1-x^n}\right) - \lim_{x\to1}\left(\frac{1}{1-x} - \frac{m}{1-x^m}\right)$$

$$= \left(-\frac{n-1}{2}\right) - \left(-\frac{m-1}{2}\right) = \frac{-n+1+m-1}{2} = \frac{m-n}{2}$$

ដូចនេះ $\boxed{\lim_{x\to1}\left(\frac{m}{1-x^m} - \frac{n}{1-x^n}\right) = \frac{m-n}{2}}$ ។

លំហាត់ទី៣

ចូរគណនាលីមីតខាងក្រោម :

ក. $\lim\limits_{x\to0}\frac{1-(1+x)(1+2x)(1+3x)}{x}$

ខ. $\lim\limits_{x\to0}\frac{1-(1+x)(1+2x)(1+3x)......(1+nx)}{x}, n\in IN^*$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to0}\frac{1-(1+x)(1+2x)(1+3x)}{x}$

$$=\lim\limits_{x\to0}\frac{1-(1+x)+(1+x)[1-(1+2x)]+(1+x)(1+2x)[1-(1+3x)]}{x}$$

$$=\lim\limits_{x\to0}\frac{-x-2x(1+x)-3x(1+x)(1+2x)}{x}$$

$$=-\lim\limits_{x\to0}\left[1+2(1+x)+3(1+x)(1+2x)\right]=-(1+2+3)=-6$$

ដូចនេះ $\boxed{\lim\limits_{x\to0}\frac{1-(1+x)(1+2x)(1+3x)}{x}=-6}$ ។

ខ. $\lim\limits_{x\to0}\frac{1-(1+x)(1+2x)(1+3x)......(1+nx)}{x}, n\in IN^*$

$$=\lim\limits_{x\to0}\frac{1-(1+x)+(1+x)[1-(1+2x)]+...+(1+x)(1+2x)...(1+(n-1)x)[1-(1+nx)]}{x}$$

$$=\lim\limits_{x\to0}\frac{-x-2x(1+x)-.....-nx(1+x)(1+2x)....(1+(n-1)x)}{x}$$

$$=-\lim\limits_{x\to0}\left[1+2(1+x)+3(1+x)(1+2x)+....+n(1+x)(1+2x)...(1+(n-1)x\right]$$

$$=-(1+2+3+.....+n)=-\frac{n(n+1)}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to1}\frac{1-(1+x)(1+2x)(1+3x)....(1+nx)}{x}=-\frac{n(n+1)}{2}}$ ។

លំហាត់ទី៤

ចូរគណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}$

ខ. $\lim_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2}\ ,\ n\in IN^*$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}$

$=\lim_{x\to 0}\dfrac{1+3x+3x^2+x^3-3x-1}{x^2}$

$=\lim_{x\to 0}\dfrac{3x^2+x^3}{x^2}=\lim_{x\to 0}(3+x)=3$

ដូចនេះ $\boxed{\lim_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}=3}$ ។

ខ. $\lim_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2}\ ,\ n\in IN^*$

តាមរូបមន្តទ្វេធាញូតុន $(1+x)^n=C_n^0+C_n^1x+C_n^2x^2+C_n^3x^3+\ldots+C_n^nx^n$

$=\lim_{x\to 0}\dfrac{1+nx+\dfrac{n(n-1)}{2}x^2+C_n^3x^3+\ldots.+C_n^nx^n-nx-1}{x^2}$

$=\lim_{x\to 0}\dfrac{\dfrac{n(n-1)}{2}x^2+C_n^3x^3+\ldots.+C_n^nx^n}{x^2}$

$=\lim_{x\to 0}\left[\dfrac{n(n-1)}{2}+C_n^3x+\ldots.+C_n^nx^{n-2}\right]=\dfrac{n(n-1)}{2}$

ដូចនេះ $\boxed{\lim_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2}=\dfrac{n(n-1)}{2}}$ ។

លំហាត់ទី៥

ចូរគណនាលីមីតខាងក្រោម :

ក. $\lim\limits_{x\to 1}\dfrac{3x^4-4x^3+1}{(x-1)^2}$

ខ. $\lim\limits_{x\to 1}\dfrac{nx^{n+1}-(n+1)x^n+1}{(x-1)^2}$, $n\in IN^*$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម :

ក. $\lim\limits_{x\to 1}\dfrac{3x^4-4x^3+1}{(x-1)^2}$

$$=n.\left(1+\frac{2x}{2\sqrt{1+x^2}}\right).(x+\sqrt{1+x^2})^{n-1}$$

$$=n.\frac{\sqrt{1+x^2}+x}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^{n-1}$$

$$=\frac{n}{\sqrt{1+x^2}}(x+\sqrt{1+x^2})^n$$

ដូចនេះ $\boxed{f'(x)=\frac{n}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^n}$ ។

គេមាន $f'(x)=\frac{n}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^n$ ដោយ $f(x)=(x+\sqrt{1+x^2})^n$

គេបាន $f'(x)=\frac{n}{\sqrt{1+x^2}}.f(x)$ នាំឱ្យ $\sqrt{1+x^2}.f'(x)=n.f(x)$ ។

ដូចនេះ $\boxed{\sqrt{1+x^2}.f'(x)=n.f(x)}$ ។

ខ-ស្រាយបញ្ជាក់ទំនាក់ទំនង :

$$(1+x^2).f''(x)+x.f'(x)=n^2.f(x)$$

គេមាន $\sqrt{1+x^2}.f'(x)=n.f(x)$ នាំឱ្យ $f'(x)=n.\dfrac{f(x)}{\sqrt{1+x^2}}$

គេបាន $f''(x)=n.\dfrac{f'(x)\sqrt{1+x^2}-(\sqrt{1+x^2})'f(x)}{(\sqrt{1+x^2})^2}$

$$f''(x)=n\frac{f'(x).\sqrt{1+x^2}-\dfrac{2x}{2\sqrt{1+x^2}}.f(x)}{1+x^2}$$

$$f''(x)=n.\frac{\sqrt{1+x^2}.f'(x)-x.\dfrac{f(x)}{\sqrt{1+x^2}}}{1+x^2} \quad (1)$$

គេមាន $\sqrt{1+x^2}.f'(x)=n.f(x)$ (2) និង $\dfrac{1}{n}.f'(x)=\dfrac{f(x)}{\sqrt{1+x^2}}$ (3)

យក (2) និង (3) ជួសក្នុងទំនាក់ទំនង (1) គេបាន :

$$f''(x)=n.\frac{n.f(x)-x.\dfrac{1}{n}f'(x)}{1+x^2}$$

នាំឱ្យ $(1+x^2).f''(x)=n^2.f(x)-x.f'(x)$

ដូចនេះ $\boxed{(1+x^2).f''(x)+x.f'(x)=n^2.f(x)}$ ។

ꕤꕤꕤ✡ꕤꕤꕤ

លំហាត់ទី៨

គេឱ្យ f ជាអនុគមន៍កំនត់លើ IR ដោយ $f(x)=\sqrt{4x+\sqrt{16x^2+9}}$ ។

ចូរស្រាយបញ្ជាក់ថា : $(16x^2+9).f''(x)+16x.f'(x)=4f(x)$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា : $(16x^2+9).f''(x)+16x.f'(x)=4f(x)$

គេមាន $f(x)=\sqrt{4x+\sqrt{16x^2+9}}$

គេបាន $f'(x)=\dfrac{(4x+\sqrt{16x^2+9})'}{2\sqrt{4x+\sqrt{16x^2+9}}}$

$$=\frac{4+\dfrac{32x}{2\sqrt{16x^2+9}}}{2\sqrt{4x+\sqrt{16x^2+9}}}=\frac{4+\dfrac{16x}{\sqrt{16x^2+9}}}{2\sqrt{4x+\sqrt{16x^2+9}}}$$

$$=\frac{4(\sqrt{16x^2+9}+4x)}{2\sqrt{4x+\sqrt{16x^2+9}}.\sqrt{16x^2+9}}=\frac{2(\sqrt{4x+\sqrt{16x^2+9}})}{\sqrt{16x^2+9}}$$

គេទាញ $f'(x)=\dfrac{2f(x)}{\sqrt{16x^2+9}}$ ព្រោះ $f(x)=\sqrt{4x+\sqrt{16x^2+9}}$

គេបាន $f''(x)=2\dfrac{f'(x).\sqrt{16x^2+9}-\dfrac{32x}{2\sqrt{16x^2+9}}.f(x)}{16x^2+9}$

$$(16x^2+9).f''(x)=2.\sqrt{16x^2+9}.f'(x)-16x.\frac{2f(x)}{\sqrt{16x^2+9}}\quad(1)$$

ដោយ $f'(x)=\dfrac{2f(x)}{\sqrt{16x^2+9}}$ (2) នាំឱ្យ $\sqrt{16x^2+9}.f'(x)=2f(x)$ (3)

យកទំនាក់ទំនង (2) និង (3) ជួសក្នុង (1) គេបាន :

ដូចនេះ $\boxed{(16x^2+9).f''(x)+16x.f'(x)=4f(x)}$ ។

លំហាត់ទី៩

គេឱ្យ f ជាអនុគមន៍កំនត់ដោយ $f(x)=\dfrac{1+\sin x}{2+\sin x-\cos x}$

កំនត់គ្រប់ $x\in IR$ ។

ក-គណនាដេរីវេ $f'(x)$ ។

ខ-គណនាតម្លៃ $f'(0)$ និង $f'\left(\dfrac{\pi}{2}\right)$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$

គេមាន $f(x)=\dfrac{1+\sin x}{2+\sin x-\cos x}$ គេបាន ៖

$$f'(x)=\frac{(1+\sin x)'(2+\sin x-\cos x)-(2+\sin x-\cos x)'(1+\sin x)}{(2+\sin x-\cos x)^2}$$

$$=\frac{\cos x.(2+\sin x-\cos x)-(\cos x+\sin x)(1+\sin x)}{(2+\sin x-\cos x)^2}$$

$$=\frac{2\cos x+\sin x\cos x-\cos^2 x-\cos x-\sin x\cos x-\sin x-\sin^2 x}{(2+\sin x-\cos x)^2}$$

$$=\frac{\cos x-\sin x-(\cos^2 x+\sin^2 x)}{(2+\sin x-\cos x)^2}=\frac{\cos x-\sin x-1}{(2+\sin x-\cos x)^2}$$

ដូចនេះ $\boxed{f'(x)=\dfrac{\cos x-\sin x-1}{(2+\sin x-\cos x)^2}}$ ។

ខ-គណនាតម្លៃ $f'(0)$ និង $f'\left(\dfrac{\pi}{2}\right)$

គេបាន $f'(0)=\dfrac{\cos 0-\sin 0-1}{(2+\sin 0-\cos 0)^2}=\dfrac{1-0-1}{(2+0-1)^2}=0$

និង $f'\left(\dfrac{\pi}{2}\right)=\dfrac{\cos\dfrac{\pi}{2}-\sin\dfrac{\pi}{2}-1}{(2+\sin\dfrac{\pi}{2}-\cos\dfrac{\pi}{2})^2}=\dfrac{0-1-1}{(2+1-0)^2}=-\dfrac{2}{9}$ ។

លំហាត់ទី១០

គេមានអនុគមន៍ $f(x)=\dfrac{\cos x}{1+\sin x}$

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$

ខ-គណនាតម្លៃ $f'(0)$ និង $f''(0)$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេមាន $f(x)=\dfrac{\cos x}{1+\sin x}$

គេបាន $f'(x)=\dfrac{(\cos x)'(1+\sin x)-(1+\sin x)'(\cos x)}{(1+\sin x)^2}$

$$=\frac{-\sin x-\sin^2 x-\cos^2 x}{(1+\sin x)^2}=-\frac{\sin x+(\sin^2 x+\cos^2 x)}{(1+\sin x)^2}$$

$$=-\frac{\sin x+1}{(1+\sin x)^2}=-\frac{1}{1+\sin x}$$

ដូចនេះ $\boxed{f'(x)=-\dfrac{1}{1+\sin x}}$ ។

ម្យ៉ាងទៀត $f''(x)=(-\dfrac{1}{1+\sin x})'=\dfrac{(1+\sin x)'}{(1+\sin x)^2}=\dfrac{\cos x}{(1+\sin x)^2}$

ដូចនេះ $\boxed{f''(x)=\dfrac{\cos x}{(1+\sin x)^2}}$

ខ-គណនាតម្លៃ $f'(0)$ និង $f''(0)$

គេបាន $f'(0)=-\dfrac{1}{1+\sin 0}=-\dfrac{1}{1+0}=-1$

និង $f''(0)=\dfrac{\cos 0}{(1+\sin 0)^2}=\dfrac{1}{(1+0)^2}=1$ ។

ដូចនេះ $f'(0)=-1$ និង $f''(0)=1$ ។

លំហាត់ទី១១

ចូរគណនាដេរីវេនៃអនុគមន៍ ៖

$f(x)=\sin^{n+1}x.\sin(n+1)x$ និង $g(x)=\cos^{n+1}x.\cos(n+1)x$

ដែល n ជាចំនួនគត់ធម្មជាតិ ។

ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍ ៖

គេមាន $f(x)=\sin^{n+1}x.\sin(n+1)x$

គេបាន $f'(x)=(\sin^{n+1}x)'.\sin(n+1)x+(\sin(n+1)x)'.\sin^{n+1}x$

$$=(n+1)\cos x.\sin^{n}x.\sin(n+1)x+(n+1).\cos(n+1)x.\sin^{n+1}x$$

$$=(n+1).\sin^{n}x.\left[\sin(n+1)x.\cos x+\sin x.\cos(n+1)x\right]$$

$$=(n+1).\sin^{n}x.\sin\left((n+1)x+x\right)=(n+1).\sin^{n}x.\sin(n+2)x$$

ដូចនេះ $\boxed{f'(x)=(n+1).\sin^{n}x.\sin(n+2)x}$ ។

គេមាន $g(x)=\cos^{n+1}x.\cos(n+1)x$

គេបាន $g'(x)=(\cos^{n+1}x)'.\cos(n+1)x+(\cos(n+1)x)'.\cos^{n+1}x$

$$=-(n+1)\sin x.\cos^{n}x.\cos(n+1)x-(n+1).\sin(n+1)x.\cos^{n+1}x$$

$$=-(n+1).\cos^{n}x.\left[\sin x.\cos(n+1)x+\sin(n+1)x.\cos x\right]$$

$$-(n+1).\cos^{n}x.\sin\left(x+(n+1)x\right)=-(n+1).\cos^{n}x.\sin(n+2)x$$

ដូចនេះ $\boxed{g'(x)=-(n+1).\cos^{n}x.\sin(n+2)x}$ ។

លំហាត់ទី១២

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+mx+4}{x^2+1}$

ដែល x ជាចំនួនពិត និង m ជាប៉ារ៉ាម៉ែត្រ ។

ក-ចូរកំនត់តម្លៃ m ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាត្រង់ចំនុច $x=2$

ខ-ចូរកំនត់តម្លៃ m ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់ ។

ដំណោះស្រាយ

ក-កំនត់តម្លៃ m

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាត្រង់ចំនុច $x=2$ លុះត្រាតែ $f'(2)=0$

គេមាន $f(x)=\dfrac{x^2+mx+4}{x^2+1}$

គេបាន $f'(x)=\dfrac{(x^2+mx+4)'(x^2+1)-(x^2+1)'(x^2+mx+4)}{(x^2+1)^2}$

$$=\frac{(2x+m)(x^2+1)-2x(x^2+mx+4)}{(x^2+1)^2}$$

$$=\frac{2x^3+2x+mx^2+m-2x^3-2mx^2-8x}{(x^2+1)^2}$$

$$f'(x)=\frac{-mx^2-6x+m}{(x^2+1)^2}$$

ចំពោះ $x=2$ គេបាន $f'(2)=\dfrac{-4m+12+m}{(4+1)^2}=\dfrac{12-3m}{25}=0$

នាំឱ្យ $\boxed{m=4}$ ។

ខ-កំនត់តម្លៃ m

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់លុះត្រាតែសមីការ $f'(x)=0$ សមមូល $-mx^2+6x+m=0$ មានឫសតែមួយគត់ ពោលគឺត្រូវឱ្យ $m=0$ ។

លំហាត់ទី១៣

គេឱ្យអនុគមន៍ $f(x)=\dfrac{ax^2+bx+3}{x^2+4}$

ចូរកំនត់តម្លៃនៃចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ f មានចំនុចបរមាតែមួយគត់ ហើយខ្សែកោងរបស់វាមានបន្ទាត់ $y=2$ ជាអាស៊ីមតូតដេក ។

ដំណោះស្រាយ

កំនត់តម្លៃនៃចំនួនពិត a និង b

គេមាន $f(x)=\dfrac{ax^2+bx+3}{x^2+4}$

គេបាន $f'(x)=\dfrac{(2ax+b)(x^2+4)-2x(ax^2+bx+3)}{\left(x^2+4\right)^2}$

$$\frac{2ax^3+8ax+bx^2+4b-2ax^3-2bx^2-6x}{(x^2+4)^2}$$

$$=\frac{-bx^2+(8a-6)x+4b}{(x^2+4)^2}$$

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់លុះត្រាតែសមីការ $f'(x)=0$ មានឫសតែមួយគត់ ។

ដោយ $f'(x)=\dfrac{-bx^2+(8a-6)x+4b}{(x^2+4)^2}=0$

នាំឱ្យ $-bx^2+(8a-6)x+4b=0$ មានឫសទោលតែមួយគត់លុះត្រាតែ $b=0$ ។

ម្យ៉ាងទៀតខ្សែកោងរបស់វាមានបន្ទាត់ $y=2$ ជាអាស៊ីមតូតដេកលុះត្រាតែ $\lim\limits_{x\to\infty} f(x)=2$ ។

គេបាន $\lim\limits_{x\to\infty} f(x)=\lim\limits_{x\to\infty}\dfrac{ax^2+bx+3}{x^2+4}=\lim\limits_{x\to\infty}\dfrac{ax^2}{x^2}=a=2$ ។

ដូចនេះ $\boxed{a=2\ ,b=0}$ ។

លំហាត់ទី១៤

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+px+q}{x}$ ដែល x ជាចំនួនពិតខុសពីសូន្យ ។

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$ ។

ខ-ចូរកំនត់ចំនួនពិត p និង q ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអតិបរមាស្មើ 1 ចំពោះ $x=-2$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេមាន $f(x)=\dfrac{x^2+px+q}{x}=x+p+\dfrac{q}{x}$ គ្រប់ $x\neq 0$ ។

គេបាន $f'(x)=(x+p+\dfrac{q}{x})'=1-\dfrac{q}{x^2}$ និង $f''(x)=(1-\dfrac{q}{x^2})'=\dfrac{2q}{x^3}$

ដូចនេះ $\boxed{f'(x)=1-\dfrac{q}{x^2}\quad ,f''(x)=\dfrac{2q}{x^3}}$ ។

ខ-កំនត់ចំនួនពិត p និង q

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអតិបរមាស្មើ 1 ចំពោះ $x=-2$

លុះត្រាតែ $\begin{cases} f'(-2)=0 \\ f(-2)=1 \\ f''(-2)<0 \end{cases}$

គេទាញបាន $\begin{cases} f'(-2)=1-\dfrac{q}{4}=0 \\ f(-2)=\dfrac{4-2p+q}{-2}=1 \\ f''(-2)=\dfrac{2q}{-8} \end{cases}$ នាំឱ្យ $\begin{cases} q=4 \\ p=5 \\ f''(-2)=-\dfrac{q}{4}=-\dfrac{4}{4}=-1<0 \end{cases}$

ដូចនេះ $\boxed{p=5\quad ,q=4}$ ។

លំហាត់ទី១៥

គេឱ្យអនុគមន៍ $f(x)=ax+1+\dfrac{b}{x}$ ដែល x ជាចំនួនពិតខុសពីសូន្យ ។

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$ ។

ខ-ចូរកំនត់ចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ 5 ចំពោះ $x=1$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេមាន $f(x)=ax+1+\frac{b}{x}$

គេបាន $f'(x)=(ax+1+\frac{b}{x})'=a-\frac{b}{x^2}$ និង $f''(x)=(a-\frac{b}{x^2})'=\frac{2b}{x^3}$

ដូចនេះ $\boxed{f'(x)=a-\frac{b}{x^2}\ ,f''(x)=\frac{2b}{x^3}}$ ។

ខ-កំនត់ចំនួនពិត a និង b

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ 5 ចំពោះ $x=1$

លុះត្រាតែ $\begin{cases} f'(1)=0 \\ f(1)=5 \\ f''(1)>0 \end{cases}$

គេបាន $\begin{cases} f'(1)=a-b=0 \\ f(1)=a+1+b=5 \\ f''(1)=2b \end{cases}$ នាំឱ្យ $\begin{cases} a-b=0 \\ a+b=4 \\ f''(1)=2b \end{cases}$ ឬ $\begin{cases} a=2 \\ b=2 \\ f''(1)=4>0 \end{cases}$

ដូចនេះ $\boxed{a=2\ ,b=2}$ ។

លំហាត់ទី១៦

គេឱ្យអនុគមន៍ $y = f(x) = \dfrac{x^2 + ax + b}{x^2 + 1}$ មានក្រាបតំនាង (c) ក្នុងតម្រុយអរតូនរមេមួយ ។

ក-ខ្សែកោង (c) កាត់អក្ស័អាប់ស៊ីស $(x'0x)$ ត្រង់ចំនុចមានអាប់ស៊ីស $x = \alpha$ ។

បង្ហាញថាបន្ទាត់ប៉ះ (c) ត្រង់ $x = \alpha$ មានមេគុណប្រាប់ទិស $k = \dfrac{2\alpha + a}{\alpha^2 + 1}$ ។

ខ-ចូរកំនត់តម្លៃ a និង b ដើម្បីឱ្យខ្សែកោង (c) កាត់អក្ស័អាប់ស៊ីស បានពីរចំនុច M និង N ដែលបន្ទាត់ប៉ះ (c) ត្រង់ M និង N កែងនឹងគ្នា ។

ដំណោះស្រាយ

បង្ហាញថាបន្ទាត់ប៉ះ (c) ត្រង់ $x = \alpha$ មានមេគុណប្រាប់ទិស $k = \dfrac{2\alpha + a}{\alpha^2 + 1}$

គេមាន $f(x) = \dfrac{x^2 + ax + b}{x^2 + 1}$

គេបាន $f'(x) = \dfrac{(x^2 + ax + b)'(x^2 + 1) - (x^2 + 1)'(x^2 + ax + b)}{(x^2 + 1)^2}$

$$= \frac{(2x + a)(x^2 + 1) - 2x(x^2 + ax + b)}{(x^2 + 1)^2}$$

បើ k ជាមេគុណប្រាប់ទិសនៃ បន្ទាត់ប៉ះ (c) ត្រង់ $x = \alpha$ គេបាន $k = f'(\alpha)$

គេបាន $k = \dfrac{(2\alpha + a)(x^2 + 1) - 2\alpha.(\alpha^2 + a\alpha + b)}{(\alpha^2 + 1)^2}$ (1)

ម្យ៉ាងទៀតខ្សែកោង (c) កាត់អក្ស័អាប់ស៊ីស $(x'0x)$ ត្រង់ចំនុចមានអាប់ស៊ីស $x = \alpha$ គេបាន $f(\alpha) = \dfrac{\alpha^2 + a\alpha + b}{\alpha^2 + 1} = 0$ នាំឱ្យ $\alpha^2 + a\alpha + b = 0$ (2)

យកសមីការ (2) ជួសក្នុង (1) គេបាន $k = \dfrac{(2\alpha + a)(\alpha^2 + 1)}{(\alpha^2 + 1)^2} = \dfrac{2\alpha + a}{\alpha^2 + 1}$

ដូចនេះ $\boxed{k = \dfrac{2\alpha + a}{\alpha^2 + 1}}$ ។

ខ-កំនត់តម្លៃ a និង b

សមីការអាប់ស៊ីសចំនុចប្រសព្វ M និង N រវាងខ្សែកោង (c) ជាមួយ(x'0x) :

$$f(x) = \frac{x^2 + ax + b}{x^2 + 1} = 0 \quad \text{ឬ} \quad x^2 + ax + b = 0 \quad (E)$$

តាង k_1 និង k_2 ជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ (c) ត្រង់ M និង N គេបាន

$$k_1 = f'(x_M) = \frac{2x_M + a}{x_M^2 + 1} \text{ និង } k_2 = f'(x_N) = \frac{2x_N + a}{x_N^2 + 1}$$

(តាមសម្រាយខាងលើ) ។

ដើម្បីឱ្យបន្ទាត់ប៉ះនេះកែងគ្នាលុះត្រាតែ

$$k_1.k_2 = \left(\frac{2x_M + a}{x_M^2 + 1}\right).\left(\frac{2x_N + a}{x_N^2 + 1}\right) = -1$$

នាំឱ្យ $(2x_M + a)(2x_N + a) = -(x_M^2 + 1)(x_N^2 + 1)$

$$(2x_M + a).(2x_N + a) + (x_M^2 + 1)(x_N^2 + 1) = 0$$

$$4x_M x_N + 2a(x_M + x_N) + a^2 + x_M^2 x_N^2 + \left(x_M^2 + x_N^2\right) + 1 = 0$$

$$4x_M x_N + 2a(x_M + x_N) + a^2 + x_M^2 x_N^2 + \left[(x_M + x_N)^2 - 2x_M x_N\right] + 1 = 0$$

$$(x_M + x_N)^2 + x_M^2 x_N^2 + 2a(x_M + x_N) + 2x_M x_N + a^2 + 1 = 0 \quad (3)$$

ដោយ x_M និង x_N ជាឫសសមីការ (E) នោះគេមាន $\begin{cases} x_M + x_N = -a \\ x_M x_N = b \end{cases}$

ទំនាក់ទំនង (3) អាចសរសេរ :

$$a^2 + b^2 - 2a^2 + 2b + a^2 + 1 = 0$$

$$b^2 + 2b + 1 = (b+1)^2 = 0 \quad \text{នាំឱ្យ} \quad b = -1$$

ម្យ៉ាងទៀតដើម្បីឱ្យ (c) កាត់អក្ស័ (x'0x) បានពីរចំនុចM និង N លុះត្រាតែ

សមីការ (E) មានឫសពីរផ្សេងគ្នា ពោលគឺគេត្រូវឱ្យ $\Delta = a^2 - 4b > 0$

ដោយ $b = -1$ គេទាញបាន $\Delta = a^2 + 4 > 0$ ពិតជានិច្ចគ្រប់ចំនួនពិត a ។

ដូចនេះ $\boxed{a \in IR \ , b = -1}$ ។

លំហាត់ទី១៧

គេឱ្យអនុគមន៍ $f(x) = (ax+b).e^x$ ដែល $a \neq 0, a, b \in IR$

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអតិបរមាស្មើ $2e$

ចំពោះ $x = 1$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេបាន $f'(x) = (ax+b)'e^x + (e^x)'(ax+b)$

$$= ae^x + e^x(ax+b)$$

$$= (ax+a+b).e^x$$

និង $f''(x) = (ax+a+b)'e^x + (e^x)'(ax+a+b)$

$$= a.e^x + e^x(ax+a+b)$$

$$= (ax+2a+b).e^x$$

ដូចនេះ $\boxed{f'(x) = (ax+a+b)e^x \ , f''(x) = (ax+2a+b)e^x}$ ។

ខ-កំនត់ចំនួនពិត a និង b

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអតិបរមាស្មើ $2e$ ចំពោះ $x=1$

លុះត្រាតែ $\begin{cases} f'(1)=0 \\ f(1)=2e \\ f''(1)<0 \end{cases}$ គេបាន $\begin{cases} f'(1)=(2a+b)e=0 \\ f(1)=(a+b)e=2e \\ f''(1)<0 \end{cases}$

ឬ $\begin{cases} 2a+b=0 \\ a+b=2 \\ f''(1)=(3a+b)e \end{cases}$ នាំឱ្យ $\begin{cases} a=-2 \\ b=4 \\ f''(1)=-2e<0 \end{cases}$

ដូចនេះ $\boxed{a=-2\ ,b=4}$ ។

លំហាត់ទី១៨

គេឱ្យអនុគមន៍ $f(x)=\dfrac{e^x}{ax+b}$ ដែល $a\neq 0, a, b\in IR$

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ e ចំពោះ $x=1$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេបាន $f'(x)=\dfrac{(e^x)'(ax+b)-(ax+b)'e^x}{(ax+b)^2}$

$$=\frac{e^x(ax+b)-ae^x}{(ax+b)^2}=\frac{(ax+b-a).e^x}{(ax+b)^2}$$

ដូចនេះ $\boxed{f'(x)=\dfrac{(ax+b-a).e^x}{(ax+b)^2}}$ ។

$$f''(x)=\frac{[(ax+b-a)e^x]'(ax+b)^2-[(ax+b)^2]'(ax+b-a)e^x}{(ax+b)^4}$$

$$=\frac{[ae^x+e^x(ax+b-a)](ax+b)^2-2a(ax+b)(ax+b-a)e^x}{(ax+b)^4}$$

$$=\frac{(ax+b)^2.e^x-2a(ax+b-a)e^x}{(ax+b)^3}=\frac{\left[(ax+b)^2-2a(ax+b-a)\right].e^x}{(ax+b)^3}$$

ដូចនេះ $\boxed{f''(x)=\dfrac{\left[(ax+b)^2-2a(ax+b-a)\right]e^x}{(ax+b)^3}}$ ។

ខ-កំនត់ចំនួនពិត a និង b

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ e ចំពោះ $x=1$

លុះត្រាតែ $\begin{cases} f'(1)=0 \\ f(1)=e \\ f''(1)>0 \end{cases}$ បន្ទាប់ពីដោះស្រាយគេបាន $\boxed{a=1\ ,b=0}$ ។

លំហាត់ទី១៩

គេឱ្យ f ជាអនុគមន៍កំនត់លើ IR ដោយ $f(x)=(x-2)(e^x+1)$

ចូរសរសេរសមីការបន្ទាត់ (T) ដែលស្របនឹងបន្ទាត់ $(d): y=x-2$

ហើយប៉ះនឹងក្រាប (c) តំនាងអនុគមន៍ $y=f(x)$ ។

ដំណោះស្រាយ

សរសេរសមីការបន្ទាត់ (T) :

តាង $M_0(x_0, y_0)$ ជាចំនុចប៉ះរវាងបន្ទាត់ (T) ទៅនឹងខ្សែកោង (c) ។

តាមរូបមន្ត $(T): y - y_0 = f'(x_0).(x - x_0)$

ដោយគេមាន $(T)//(d): y = x - 2$ នាំឱ្យគេទាញបាន $f'(x_0) = 1$

(មេគុណប្រាប់ទិសស្មើគ្នា) ។

គេមាន $f(x) = (x-2)(e^x + 1)$

គេបាន
$$f'(x) = (x-2)'(e^x + 1) + (e^x + 1)'(x-2)$$
$$= e^x + 1 + e^x(x-2)$$
$$= 1 + (x-1).e^x$$

គេទាញ $f'(x_0) = 1 + (x_0 - 1).e^{x_0} = 1$ ឬ $(x_0 - 1).e^{x_0} = 0$ នាំឱ្យ $x_0 = 1$

ចំពោះ $x_0 = 1$ គេបាន $y_0 = f(1) = (1-2).e = -e$ ។

សមីការបន្ទាត់ (T) អាចសរសេរ $(T): y + e = 1.(x-1)$ ឬ $y = x - 1 - e$

ដូចនេះ $\boxed{(T): y = x - 1 - e}$ ។

លំហាត់ទី២០

គេឱ្យ f ជាអនុគមន៍កំនត់ដោយ $f(x)=\sin^6 x+\cos^6 x+k.\sin^2 x.\cos^2 x$

ក-ចូរគណនាដេរីវេ $f'(x)$ ។

ខ-ចូរកំនត់ចំនួនពិត k ដើម្បីឱ្យ $f(x)$ ជាអនុគមន៍ថេរជានិច្ចចំពោះគ្រប់ $x\in IR$ ។

ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$

$$
\begin{aligned}
f'(x) &= 6.(\sin x)'\sin^5 x+6.(\cos x)'\cos^5 x+k(\sin^2 x)'\cos^2 x+k(\cos^2 x)'\sin^2 x \\
&= 6\cos x\sin^5 x-6\sin x\cos^5 x+2k\sin x\cos^3 x-2k\cos x\sin^3 x \\
&= 6\cos x\sin x(\sin^4 x-\cos^4 x)+2k\sin x\cos x(\cos^2 x-\sin^2 x) \\
&= 3\sin 2x(\sin^2 x-\cos^2 x)(\sin^2 x+\cos^2 x)+k\sin 2x.\cos 2x \\
&= 3\sin 2x(-\cos 2x)+k\sin 2x\cos 2x \\
&= -3\sin 2x\cos 2x+k.\sin 2x\cos 2x \\
&= (-3+k).\sin 2x\cos 2x=\frac{1}{2}(k-3)\sin 4x
\end{aligned}
$$

ដូចនេះ $\boxed{f'(x)=\frac{1}{2}(k-3).\sin 4x}$ ។

ខ-កំនត់ចំនួនពិត k

ដើម្បីឱ្យ $f(x)$ ជាអនុគមន៍ថេរជានិច្ចចំពោះគ្រប់ $x\in IR$ លុះត្រាតែ

$f'(x)=0$ គ្រប់ $x\in IR$ ។

ដោយ $f'(x)=\frac{1}{2}(k-3).\sin 4x$ គេទាញ $k-3=0$ នាំឱ្យ $k=3$ ។

លំហាត់ទី២១

គេឱ្យអនុគមន៍ $\mathbf{f(x)=ax+b-\frac{\ln x}{x}}$ ដែល $x>0$ ហើយ a និង b ជាចំនួនពិត ។

ក-បង្ហាញថាចំពោះគ្រប់ចំនួនពិត a និង b ដែល $a \neq 0$ ខ្សែកោង (C) តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេតមួយដែលគេនឹងបញ្ជាក់សមីការ ។

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង (C) តាងអនុគមន៍ $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y=x+4$ ត្រង់ចំនុច $A(1,5)$ ។

ដំណោះស្រាយ

ក-បង្ហាញថាខ្សែកោង (C) តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេតមួយ

គេមាន $\mathbf{f(x)=ax+b-\frac{\ln x}{x}}$ ដែល $x>0$

ដោយ $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$ នាំឱ្យបន្ទាត់ $y=ax+b$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង (C) ។

ដូចនេះ ខ្សែកោង (C) តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេត $y=ax+b$ ។

ខ-កំនត់ចំនួនពិត a និង b

គេមាន $f(x)=ax+b-\frac{\ln x}{x}$

គេបាន $f'(x) = (ax+b)' - \frac{(\ln x)'.x - (x)'.\ln x}{x^2} = a - \frac{1-\ln x}{x^2}$ ។

ដើម្បីឱ្យខ្សែកោង (C) តាងអនុគមន៍ $f(x)$ ប៉ះទៅនឹងបន្ទាត់

$(T): y = x + 4$

ត្រង់ចំនុច $A(1,5)$ លុះត្រាតែ $\begin{cases} f'(x_A) = a_T \\ f(x_A) = y_A \end{cases}$ នាំឱ្យ $\begin{cases} a - \frac{1-\ln 1}{1^2} = 1 \\ a.1 + b - \frac{\ln 1}{1} = 5 \end{cases}$

ឬ $\begin{cases} a - 1 = 1 \\ a + b = 5 \end{cases}$ ឬ $\begin{cases} a = 2 \\ b = 3 \end{cases}$

ដូចនេះ $\boxed{a = 2 \ , b = 3}$ ។

លំហាត់ទី២២

គេឱ្យអនុគមន៍ $f(x) = \frac{x^2 + px + q}{x - 2}$ ដែល $x \neq 2$ ។

ក-ចូរគណនាដើរវេ $f'(x)$ ។

ខ-ចូរកំនត់ចំនួនពិត p និង q ដើម្បីឱ្យ $f'(x) = \frac{x^2 - 4x + 3}{(x-2)^2}$ និង $f(3) = 3$ ។

ដំណោះស្រាយ

ក-គណនាដើរវេ $f'(x)$

គេមាន $f(x) = \frac{x^2 + px + q}{x - 2}$ ដែល $x \neq 2$

គេបាន $f'(x) = \frac{(x^2 + px + q)'(x-2) - (x-2)'(x^2 + px + q)}{(x-2)^2}$

$$=\frac{(2x+p)(x-2)-(x^2+px+q)}{(x-2)^2}$$

$$=\frac{2x^2-4x+px-2p-x^2-px-q}{(x-2)^2}=\frac{x^2-4x-2p-q}{(x-2)^2}$$

ដូចនេះ $\boxed{f'(x)=\frac{x^2-4x-2p-q}{(x-2)^2}}$ ។

ខ-កំនត់ចំនួនពិត p និង q

ដោយ $f'(x)=\frac{x^2-4x+3}{(x-2)^2}$ និង $f'(x)=\frac{x^2-4x-2p-q}{(x-2)^2}$

គេទាញ $\frac{x^2-4x-2p-q}{(x-2)^2}=\frac{x^2-4x+3}{(x-2)^2}$ នាំឱ្យ $-2p-q=3$ (1)

និង $f(3)=\frac{9+3p+q}{3-2}=3$ នាំឱ្យ $3p+q=-6$ (2)

បូកសមីការ (1) និង (2) គេបាន $p=-3$

បន្ទាប់មក $q=-6-3p=-6+9=3$ ។

ដូចនេះ $\boxed{p=-3\ ,q=3}$ ។

លំហាត់ទី២៣

គេឱ្យអនុគមន៍ f កំនត់លើ IR ដោយ $f(x)=\sin x$

ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$?

ដំណោះស្រាយ

បង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$

គេមាន $f(x)=\sin x$

គេបាន $f'(x)=\cos x=\sin(x+\frac{\pi}{2})$ (ព្រោះ $\sin(\frac{\pi}{2}+\theta)=\sin\theta$)

$$f''(x)=(x+\frac{\pi}{2})'\cos(x+\frac{\pi}{2})=\sin(x+\pi)$$

$$f'''(x)=(x+\pi)'\cos(x+\pi)=\sin(x+\frac{3\pi}{2})$$

ឧបមាថាវាពិតដល់ដេរីវេលំដាប់ទី n គឺ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$ ពិត

យើងនឹងស្រាយថាវាពិតដល់ដេរីវេលំដាប់ទី $(n+1)$ គឺ

$f^{(n+1)}(x)=\sin\left(x+\frac{(n+1)\pi}{2}\right)$ ពិត

យើងមាន $f^{(n+1)}(x)=(f^{(n)}(x))'$ ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$ គេបាន :

$f^{(n+1)}(x)=(x+\frac{n\pi}{2})'\cos(x+\frac{n\pi}{2})=\sin(x+\frac{n\pi}{2}+\frac{\pi}{2})=\sin\left(x+\frac{(n+1)\pi}{2}\right)$ ពិត

ដូចនេះ $\boxed{f^{(n)}(x)=\sin(x+\frac{n\pi}{2})}$ ។

លំហាត់ទី២៤

គេឱ្យអនុគមន៍ $f(x)=\dfrac{1}{2x-3}$ ដែល $x\neq\dfrac{3}{2}$

ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ

$f^{(n)}(x)=(-1)^n\dfrac{n!.2^n}{(2x-3)^{n+1}}$ ។

ដំណោះស្រាយ

បង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=(-1)^n\dfrac{n!.2^n}{(2x-3)^{n+1}}$

គេមាន $f(x)=\dfrac{1}{2x-3}$ តាមរូបមន្ត $(\dfrac{1}{v})'=-\dfrac{v'}{v^2}$

គេបាន $f'(x)=-\dfrac{(2x-3)'}{(2x-3)^2}=-\dfrac{2}{(2x-3)^2}=(-1)^1\dfrac{1!.2^1}{(2x-3)^2}$

$$f''(x)=\frac{2[(2x-3)^2]'}{(2x-3)^4}=\frac{8}{(2x-3)^3}=(-1)^2\frac{2!.2^2}{(2x-3)^3}$$

ឧបមាថាវាពិតដល់ដេរីវេលំដាប់ទី n គឺ $f^{(n)}(x)=(-1)^n\dfrac{n!.2^n}{(2x-3)^{n+1}}$ ពិត

យើងនឹងស្រាយថាវាពិតដល់ដេរីវេលំដាប់ទី $(n+1)$ គឺ

$f^{(n+1)}(x)=(-1)^{n+1}\dfrac{(n+1)!.2^{n+1}}{(2x-3)^{n+2}}$ ពិត

យើងមាន $f^{(n+1)}(x)=(f^{(n)}(x))'$ ដោយ $f^{(n)}(x)=(-1)^n\dfrac{n!.2^n}{(2x-3)^{n+1}}$

គេបាន $f^{(n+1)}(x)=-(-1)^n.\dfrac{n!.2^n[(2x-3)^{n+1}]'}{(2x-3)^{2n+2}}$

$=(-1)^{n+1}\dfrac{n!.2^n.(n+1).2}{(2x-3)^{n+2}}=(-1)^{n+1}\dfrac{(n+1)!.2^{n+1}}{(2x-3)^{n+2}}$ ពិត ។

ដូចនេះ $\boxed{f^{(n)}(x)=(-1)^n\dfrac{n!.2^n}{(2x-3)^{n+1}}}$ ។

លំហាត់ទី២៥

គេមានអនុគមន៍ $f(x)=(x+1).e^{2x}$ ដែល x ជាចំនួនពិត ។

ក. ចូរគណនាដេរីវេ $f'(x)$,$f''(x)$,$f'''(x)$ និង $f^{(4)}(x)$ ។

ខ. ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x)=(a_n x+b_n).e^{2x}$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង :

$$\begin{cases} a_{n+1}=2a_n \\ b_{n+1}=a_n+2b_n \quad ,\forall n\in IN^* \end{cases}$$

គ. ចូរកំនត់ a_n និង b_n ជាអនុគមន៍នៃ n រួចទាញរកកន្សោម $f^{(n)}(x)$ ។

ដំណោះស្រាយ

ក. គណនាដេរីវេ $f'(x)$,$f''(x)$,$f'''(x)$ និង $f^{(4)}(x)$

គេមាន $f(x)=(x+1).e^{2x}$

$$f'(x)=(x+1)'e^{2x}+(e^{2x})'(x+1)$$

$$=e^{2x}+2e^{2x}(x+1)=e^{2x}(1+2x+2)=(2x+3)e^{2x}$$

ដូចនេះ $\boxed{f'(x)=(2x+3)e^{2x}}$

គេបាន $f''(x)=(2x+3)'e^{2x}+(e^{2x})'(2x+3)$

$$=2e^{2x}+2e^{2x}(2x+3)=e^{2x}(2+4x+6)=(4x+8)e^{2x}$$

ដូចនេះ $\boxed{f''(x)=(4x+8)e^{2x}}$

គេបាន $f'''(x)=(4x+8)'e^{2x}+(e^{2x})'(4x+8)$

$= 4e^{2x} + 2e^{2x}(4x+8) = e^{2x}(4+8x+16) = (8x+20).e^{2x}$

ដូចនេះ $\boxed{f'''(x) = (8x+20)e^{2x}}$

គេបាន $f^{(4)}(x) = (8x+20)'e^{2x} + (e^{2x})'(8x+20)$

$= 8e^{2x} + 2e^{2x}(8x+20) = e^{2x}(8+16x+40) = (16x+48)e^{2x}$

ដូចនេះ $\boxed{f^{(4)}(x) = (16x+48)e^{2x}}$ ។

ខ.បង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x) = (a_n x + b_n).e^{2x}$

តាមសម្រាយខាងលើយើងមាន :

$f'(x) = (2x+3)e^{2x} = (a_1 x + b_1)e^{2x}$ ដែល $a_1 = 2$, $b_1 = 3$

$f''(x) = (4x+8)e^{2x} = (a_2 x + b_2)e^{2x}$ ដែល $a_2 = 4$, $b_2 = 8$

$f'''(x) = (8x+20)e^{2x} = (a_3 x + b_3)e^{2x}$ ដែល $a_3 = 8$, $b_3 = 20$

$f^{(4)}(x) = (16x+48)e^{2x} = (a_4 x + b_4)e^{2x}$ ដែល $a_4 = 16$, $b_4 = 48$

....

ឧបមាថាវាពិតដល់ដេរីវេលំដាប់ទី n គឺ : $f^{(n)}(x) = (a_n x + b_n)e^{2x}$ ពិត

យើងនឹងស្រាយឱ្យឃើញថាវាពិតដល់ដេរីវេលំដាប់ទី $(n+1)$ គឺ :

$f^{(n+1)}(x) = (a_{n+1} x + b_{n+1})e^{2x}$

យើងមាន $f^{(n+1)}(x) = (f^{(n)}(x))'$ ដោយ $f^{(n)}(x) = (a_n x + b_n)e^{2x}$

គេបាន $f^{(n+1)}(x) = (a_n x + b_n)'e^{2x} + (e^{2x})'(a_n x + b_n)$

$f^{(n+1)}(x) = a_n e^{2x} + 2e^{2x}(a_n x + b_n)$

$f^{(n+1)}(x) = e^{2x}(a_n + 2a_n x + 2b_n)$

$f^{(n+1)}(x) = (2a_n x + a_n + 2b_n)e^{2x}$

គេទាញ $f^{(n+1)}(x)=(a_{n+1}x+b_{n+1})e^{2x}$ ពិត

ដែល $a_{n+1}=2a_n$ និង $b_{n+1}=a_n+2b_n$ ។

ដូចនេះ ដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x)=(a_nx+b_n).e^{2x}$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង $a_{n+1}=2a_n$

និង $b_{n+1}=a_n+2b_n$ ។

គ.កំនត់ a_n និង b_n ជាអនុគមន៍នៃ n

តាមសម្រាយខាងលើគេមាន $a_{n+1}=2a_n$ និង $b_{n+1}=a_n+2b_n$

ចំពោះគ្រប់ $n\in IN^*$ ។

តាមទំនាក់ទំនង $a_{n+1}=2a_n$ នាំឱ្យ (a_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q=2$

និងតួ $a_1=2$

តាមរូបមន្ត $a_n=a_1.q^{n-1}=2.2^{n-1}=2^n$ ។

ម្យ៉ាងទៀតគេមាន $b_{n+1}=a_n+2b_n$

នាំឱ្យគេទាញ $b_{n+1}-2b_n=a_n=2^n$ ឬ $\frac{1}{2^n}b_{n+1}-\frac{1}{2^{n-1}}b_n=1$

បើគេតាង $c_n=\frac{1}{2^{n-1}}b_n$

គេបាន $c_{n+1}-c_n=1$ ថេរ នាំឱ្យ (c_n) ជាស្វ៊ីតនព្វន្តមានផលសងរួម $d=2$

និងតួ $c_1=b_1=3$

តាមរូបមន្ត $c_n=c_1+(n-1)d=3+2(n-1)=2n+1$

ដោយ $c_n=\frac{1}{2^{n-1}}b_n$ នាំឱ្យ $b_n=2^{n-1}.c_n=(2n+1).2^{n-1}$

ដូចនេះ $\boxed{a_n=2^n\ ,\ b_n=(2n+1).2^{n-1}}$ ។

ទាញរកកន្សោម $f^{(n)}(x)$ ៖

គេមាន $f^{(n)}(x)=(a_n x+b_n).e^{2x}$ ដោយ $a_n=2^n$ និង $b_n=(2n+1)2^{n-1}$

គេបាន $f^{(n)}(x)=[2^n x+(2n+1)2^{n-1}].e^{2x}=2^n(x+\frac{2n+1}{2}).e^{2x}$

ដូចនេះ $\boxed{f^{(n)}(x)=2^n(x+\frac{2n+1}{2}).e^{2x}}$ ។

លំហាត់ទី២៦

គេមានអនុគមន៍ $f(x)=e^x.\sin x$

ក. ចូរគណនាដេរីវេ $f'(x)$,$f''(x)$,$f'''(x)$ និង $f^{(4)}(x)$ ។

ខ. ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ ៖

$$f^{(n)}(x)=(a_n\sin x+b_n\cos x).e^x$$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង ៖

$$\begin{cases} a_{n+1}=a_n-b_n \\ b_{n+1}=a_n+b_n \quad ,\forall n\in IN^* \end{cases}$$

គ. គេតាង $z_n=a_n+i.b_n$ ។

ចូរបង្ហាញថា $z_{n+1}=(1+i).z_n$ រួចសរសេរ z_n ជាទម្រង់ត្រីកោណមាត្រ ។

ឃ. ចូរកំនត់ a_n និង b_n ជាអនុគមន៍នៃ n រួចទាញរកកន្សោម $f^{(n)}(x)$ ។

ដំណោះស្រាយ

ក. គណនាដេរីវេ $f'(x)$, $f''(x)$, $f'''(x)$ និង $f^{(4)}(x)$

គេមាន $f(x) = e^x.\sin x$

គេបាន $f'(x) = (e^x)'\sin x + (\sin x)'e^x$

$$= e^x \sin x + \cos x.e^x = e^x(\sin x + \cos x)$$

ដូចនេះ $\boxed{f'(x) = e^x(\sin x + \cos x)}$ ។

គេបាន $f''(x) = (e^x)'(\sin x + \cos x) + (\sin x + \cos x)'e^x$

$$= e^x(\sin x + \cos x) + (\cos x - \sin x)e^x$$

$$= e^x(\sin x + \cos x + \cos x - \sin x) = 2e^x \cos x$$

ដូចនេះ $\boxed{f''(x) = 2e^x \cos x}$ ។

គេបាន $f'''(x) = 2(e^x)'\cos x + 2(\cos x)'e^x$

$$= 2e^x \cos x - 2\sin x.e^x = 2e^x(\cos x - \sin x)$$

ដូចនេះ $\boxed{f'''(x) = 2e^x(\cos x - \sin x)}$ ។

គេបាន $f^{(4)}(x) = 2(e^x)'(\cos x - \sin x) + 2(\cos x - \sin x)'e^x$

$$= 2e^x(\cos x - \sin x) + 2(-\sin x - \cos x)e^x$$

$$= 2e^x(\cos x - \sin x - \sin x - \cos x) = -4e^x \sin x$$

ដូចនេះ $\boxed{f^{(4)}(x) = -4e^x \sin x}$ ។

ខ. បង្ហាញថាដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x) = (a_n \sin x + b_n \cos x).e^x$

តាមសម្រាយខាងលើគេមាន :

$$f'(x) = e^x(\sin x + \cos x) = (\sin x + \cos x)e^x = (a_1 \sin x + b_1 \cos x)e^x$$

ដែល $\begin{cases} a_1 = 1 \\ b_1 = 1 \end{cases}$

$$f''(x) = 2e^x \cos x = (0.\sin x + 2\cos x)e^x = (a_2 \sin x + b_2 \cos x)e^x$$

ដែល $\begin{cases} a_2 = 0 \\ b_2 = 2 \end{cases}$

$$f'''(x) = 2e^x(\cos x - \sin x) = (-2\sin x + 2\cos x)e^x = (a_3 \sin x + b_3 \cos x)e^x$$

ដែល$\begin{cases} a_3 = -2 \\ b_3 = 2 \end{cases}$

$$f^{(4)}(x) = -4e^x \sin x = (-4\sin x + 0.\cos x)e^x = (a_4 \sin x + b_4 \cos x)e^x$$

ដែល $\begin{cases} a_4 = -4 \\ b_4 = 0 \end{cases}$

....

....

ឧបមាថាវាពិតដល់ដើរវេលំដាប់ទី n គឺ $f^{(n)}(x) = (a_n \sin x + b_n \cos x).e^x$ ពិត

យើងនឹងស្រាយថាវាពិតដល់ដើរវេលំដាប់ទី $(n+1)$ គឺ

$$f^{(n+1)}(x) = (a_{n+1} \sin x + b_{n+1} \cos x)e^x$$

យើងមាន $f^{(n+1)}(x) = (f^{(n)}(x))'$

$$= (a_n \sin x + b_n \cos x)'e^x + (e^x)'(a_n \sin x + b_n \cos x)$$

$$\begin{aligned} f^{(n+1)}(x) &= (a_n \cos x - b_n \sin x)e^x + e^x(a_n \sin x + b_n \cos x) \\ &= (a_n \cos x - b_n \sin x + a_n \sin x + b_n \cos x)e^x \\ &= \left[(a_n - b_n)\sin x + (a_n + b_n)\cos x\right].e^x \end{aligned}$$

$f^{(n+1)}(x) = (a_{n+1} \sin x + b_{n+1} \cos x).e^x$ ពិត

(ព្រោះ $a_{n+1} = a_n - b_n$ និង $b_{n+1} = a_n + b_n$)

ដូចនេះ ដេរីវេទី n នៃអនុគមន៍ f មានទម្រង់ $f^{(n)}(x)=(a_n \sin x+b_n \cos x).e^x$

ដែល (a_n) និង (b_n) ជាស្វ៊ីតចំនួនពិតផ្ទៀងផ្ទាត់ទំនាក់ទំនង ៖

$$\begin{cases} a_{n+1}=a_n-b_n \\ b_{n+1}=a_n+b_n \quad ,\forall n\in IN^* \end{cases}$$

គ. បង្ហាញថា $z_{n+1}=(1+i).z_n$ សរសេរ z_n ជាទម្រង់ត្រីកោណមាត្រ ៖

គេមាន $z_n=a_n+i.b_n$ នាំឱ្យ $z_{n+1}=a_{n+1}+i.b_{n+1}$ ដោយ ៖

$$\begin{cases} a_{n+1}=a_n-b_n \\ b_{n+1}=a_n+b_n \quad ,\forall n\in IN^* \end{cases}$$

គេបាន $z_{n+1}=(a_n-b_n)+i.(a_n+b_n)$

$$=a_n-b_n+i.a_n+i.b_n=(1+i)a_n-(1-i)b_n$$

$$=(1+i)(a_n-\frac{1-i}{1+i}b_n)=(1+i)(a_n+i.b_n)=(1+i)z_n$$

ដូចនេះ $\boxed{z_{n+1}=(1+i)z_n}$ ។

ដោយគេមាន $z_{n+1}=(1+i).z_n$ នាំឱ្យ (z_n) ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច

ដែលមានរេសុង ៖

$$q=1+i=\sqrt{2}(\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2})=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$$ និងតួ $z_1=a_1+ib_1$

តែ $a_1=1, b_1=1$ នាំឱ្យ $z_1=1+i=q=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$ ។

តាមរូបមន្តតួទី n នៃស្វ៊ីតធរណីមាត្រគេអាចសរសេរ ៖

$$z_n=z_1\times q^{n-1}=\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4}).\left[\sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})\right]^{n-1}$$

$$=(\sqrt{2})^n(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})^n$$

ដូចនេះ $\boxed{z_n=\sqrt{2}^n(\cos\frac{n\pi}{4}+i.\sin\frac{n\pi}{4})}$ (តាមរូបមន្តដឺម័រ) ។

ឃ. កំនត់ a_n និង b_n ជាអនុគមន៍នៃ n

គេមាន $z_n = a_n + i.b_n$ ដោយ $z_n = \sqrt{2^n}(\cos\frac{n\pi}{4} + i.\sin\frac{n\pi}{4})$

គេទាញ $a_n + i.b_n = \sqrt{2^n}(\cos\frac{n\pi}{4} + i.\sin\frac{n\pi}{4})$ នាំឱ្យ $\begin{cases} a_n = \sqrt{2^n}.\cos\frac{n\pi}{4} \\ b_n = \sqrt{2^n}.\sin\frac{n\pi}{4} \end{cases}$

ដូចនេះ $\boxed{a_n = \sqrt{2^n}.\cos\frac{n\pi}{4} \ , b_n = \sqrt{2^n}.\sin\frac{n\pi}{4}}$ ។

ទាញរកកន្សោម $f^{(n)}(x)$ ៖

$f^{(n)}(x) = (a_n \sin x + b_n \cos x)e^x$ **ដោយ**

$a_n = \sqrt{2^n}.\cos\frac{n\pi}{4} \ , b_n = \sqrt{2^n}.\sin\frac{n\pi}{4}$

គេបាន $f^{(n)}(x) = (\sqrt{2^n}.\cos\frac{n\pi}{4}.\sin x + \sqrt{2^n}\cos x.\sin\frac{n\pi}{4}).e^x$

$$= \sqrt{2^n}(\cos\frac{n\pi}{4}\sin x + \sin\frac{n\pi}{4}\cos x).e^x = \sqrt{2^n}.\sin(x + \frac{n\pi}{4}).e^x$$

ដូចនេះ $\boxed{f^{(n)}(x) = \sqrt{2^n}.e^x \sin(x + \frac{n\pi}{4})}$ ។

លំហាត់ទី២៧

គេមានអនុគមន៍ $f(x)=\sqrt{3x+1}$ កំនត់លើ $\left[-\frac{1}{3},+\infty\right]$

ក. ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$ ។

ខ. ដោយប្រើវិសមភាពកំណើនមានកំនត់ទៅនឹងអនុគមន៍ f ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}$ ។

ដំណោះស្រាយ

ក. ចំពោះគ្រប់ $x\in[1,5]$ បង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$

គេមាន $f(x)=\sqrt{3x+1}$ នាំឱ្យ $f'(x)=\frac{3}{2\sqrt{3x+1}}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $1\le x\le 5$ ឬ $4\le 3x+1\le 16$

$$\frac{1}{4}\le\frac{1}{\sqrt{3x+1}}\le\frac{1}{2}$$

$$\frac{3}{8}\le\frac{3}{2\sqrt{3x+1}}\le\frac{3}{4}$$

ដូចនេះ $\boxed{\frac{3}{8}\le f'(x)\le\frac{3}{4}}$ ចំពោះគ្រប់ $x\in[1,5]$ ។

ខ. បង្ហាញថា $\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $\frac{3}{8}\le f'(x)\le\frac{3}{4}$

ចំពោះ $x\ge 1$ គេមាន $\frac{3}{8}(x-1)\le f(x)-f(1)\le\frac{3}{4}(x-1)$ តែ $f(x)=\sqrt{3x+1}$

គេបាន $\frac{3}{8}x-\frac{3}{8}\le\sqrt{3x+1}-2\le\frac{3}{4}x-\frac{3}{4}$

ដូចនេះ $\boxed{\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}}$ ។

លំហាត់ទី២៨

គេឱ្យអនុគមន៍ $y=f(x)=\dfrac{x^2-3x+3}{2-x}$

ក. ចូរកំនត់បីចំនួនពិត a,b និង b ដើម្បីឱ្យ $f(x)=ax+b+\dfrac{c}{2-x}$

ចំពោះគ្រប់ $x\neq 2$ ។

ខ. ចូរកំនត់សមីការអាសុីមតូតឈរ និងអាសុីមតូតទ្រេតនៃក្រាប (c)

តំនាងអនុគមន៍ f ។

គ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

ឃ. ស្រាយថាចំនុច $I(2\ ,\ -1)$ ជាផ្ចិតបំលែងឆ្លុះនៃក្រាប (c) ។

ង. ចូរសង់ក្រាប (c) តាងអនុគមន៍ $f(x)$ ក្នុងតំរុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ មួយ

ដំណោះស្រាយ

ក.កំនត់បីចំនួនពិត a,b និង b ដើម្បីឱ្យ $f(x)=ax+b+\dfrac{c}{2-x}$ ចំពោះគ្រប់ $x\neq 2$

គេមាន $y=f(x)=\dfrac{x^2-3x+3}{2-x}$

$$=\frac{(x^2-2x)-(x-2)+1}{2-x}$$

$$=\frac{x(x-2)-(x-2)+1}{2-x}=-x+1+\frac{1}{2-x}$$

គេបាន $y=f(x)=-x+1+\dfrac{1}{2-x}$ ដោយ $f(x)=ax+b+\dfrac{c}{2-x}$

ដូចនេះ $\boxed{a=-1,b=1,c=1}$ ។

ខ. កំនត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត ៖

គេមាន $f(x)=\frac{x^2-3x+3}{2-x}$

ជាអនុគមន៍កំនត់លើ $D_f=IR-\{2\}$ ។

ដោយ $\lim_{x\to 2^-} f(x)=\lim_{x\to 2^-}\frac{x^2-3x+3}{2-x}=+\infty$

និង $\lim_{x\to 2^+} f(x)=\lim_{x\to 2^+}\frac{x^2-3x+3}{2-x}=-\infty$

នាំឱ្យបន្ទាត់ $x=2$ សមីការអាស៊ីមតូតឈរនៃក្រាប (c) ។

ម្យ៉ាងទៀតគេមាន $f(x)=-x+1+\frac{1}{2-x}$

ដោយ $\lim_{x\to\pm\infty}\frac{1}{2-x}=0$

នាំឱ្យបន្ទាត់ $y=-x+1$ ជាអាស៊ីមតូតទ្រេតនៃក្រាប (c) ។

គ. គណនាដេរីវេ $f'(x)$

គេមាន $f(x)=-\frac{x^2-3x+3}{x-2}$ ជាអនុគមន៍កំនត់លើ $D_f=IR-\{2\}$

គេបាន $f'(x)=-\frac{(2x-3)(x-2)-(x^2-3x+3)}{(x-2)^2}$

$$=-\frac{2x^2-4x-3x+6-x^2+3x-3}{(x-2)^2}$$

$$=-\frac{x^2-4x+3}{(x-2)^2}$$

ដូចនេះ $\boxed{f'(x)=-\frac{x^2-4x+3}{(x-2)^2}}$ ។

គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ៖

បើ $f'(x)=-\frac{x^2-4x+3}{(x-2)^2}=0$ គេបាន $x^2-4x+3=0$

នាំឱ្យ $x_1 = 1 \ , x_2 = \frac{c}{a} = 3$

ចំពោះ $x_1 = 1$ គេបាន $f(1) = \frac{1^2 - 3 + 3}{2 - 1} = 1$

ចំពោះ $x_2 = 3$ គេបាន $f(3) = \frac{9 - 9 + 3}{2 - 3} = -3$

ដោយ $f(x) = -x + 1 + \frac{1}{2 - x}$

គេបាន $\lim\limits_{x \to \pm\infty} f(x) = \lim\limits_{x \to \pm\infty} (-x + 1 + \frac{1}{2 - x}) = \mp\infty$

គេអាចគូសតារាងអថេរភាពដូចខាងក្រោម :

x	$-\infty$		1		2		3		$+\infty$
$f'(x)$					$\Vert$				
$f(x)$	$+\infty$	$\searrow$	1	$\nearrow$	$+\infty \ \Vert \ -\infty$	$\nearrow$	-3	$\searrow$	$-\infty$

ឃ.ស្រាយថាចំនុច $I(2 \ , \ -1)$ ជាផ្ចិតបំលែងឆ្លុះនៃក្រាប (c)

គេមាន $f(x) = -x + 1 + \frac{1}{2 - x}$

តាមរូបមន្ត $f(2a - x_0) + f(x_0) = 2b$

ដើម្បីស្រាយថាចំនុច $I(2 \ , \ -1)$ ជាផ្ចិតបំលែងឆ្លុះនៃក្រាប (c) គេត្រូវស្រាយ

ឱ្យឃើញថា $f(4 - x_0) + f(x_0) = -2$ ។

$$f(4-x_0)=-(4-x_0)+1+\frac{1}{2-(4-x_0)}$$

$$=x_0-3-\frac{1}{2-x_0}=x_0-3-\frac{1}{2-x_0}$$

និង $f(x_0)=-x_0+1+\frac{1}{2-x}$ ។

គេបាន $f(4-x_0)+f(x_0)=\left(x_0-3-\frac{1}{2-x_0}\right)+\left(-x_0+1+\frac{1}{2-x_0}\right)$

ឬ $f(4-x_0)+f(x_0)=-2$ ពិត ។

ដូចនេះ ចំនុច $I(2\ ,\ -1)$ ជាផ្ចិតបំលែងឆ្លុះនៃក្រាប (c) ។

ង. សង់ក្រាប (c) តាងអនុគមន៏ $f(x)$ ក្នុងតំរុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$



លំហាត់ទី២៩

គេឱ្យអនុគមន៍ $y=f(x)=\dfrac{3(x-2)^2}{x^2-4x+3}$

ក. ចូរគណនាលីមីត $\lim\limits_{x\to1} f(x)$,$\lim\limits_{x\to3} f(x)$ និង $\lim\limits_{x\to\infty} f(x)$ រួចទាញរកសមីការ

អាស៊ីមតូតទាំងអស់នៃក្រាប(c) តាងអនុគមន៍ f ។

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ f ។

គ. បង្ហាញថាបន្ទាត់ $x=2$ ជាអក្ស័ឆ្លុះនៃក្រាប (c) ។

ឃ. ចូរសង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ ។

ដំណោះស្រាយ

ក. គណនាលីមីត $\lim\limits_{x\to1} f(x)$,$\lim\limits_{x\to3} f(x)$ និង $\lim\limits_{x\to\infty} f(x)$

គេមាន $y=f(x)=\dfrac{3(x-2)^2}{x^2-4x+3}$

គេបាន $\lim\limits_{x\to1^-} f(x)=\lim\limits_{x\to1^-}\dfrac{3(x-2)^2}{x^2-4x+3}=+\infty$

និង $\lim\limits_{x\to1^+} f(x)=\lim\limits_{x\to1^+}\dfrac{3(x-2)^2}{x^2-4x+3}=-\infty$

$\lim\limits_{x\to3^-} f(x)=\lim\limits_{x\to3^-}\dfrac{3(x-2)^2}{x^2-4x+3}=-\infty$

និង $\lim\limits_{x\to3^+} f(x)=\lim\limits_{x\to3^+}\dfrac{3(x-2)^2}{x^2-4x+3}=+\infty$

ទាញរកសមីការអាស៊ីមតូតទាំងអស់ :

ដោយគេមាន :

$\lim\limits_{x\to1^-} f(x)=+\infty$ និង $\lim\limits_{x\to1^+} f(x)=-\infty$ នាំឱ្យបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ ។

$\lim\limits_{x\to3^-} f(x) = -\infty$ និង $\lim\limits_{x\to3^+} f(x) = +\infty$ នាំឱ្យបន្ទាត់ $x=3$ ជាអាស៊ីមតូតឈរ ។

$\lim\limits_{x\to\infty} f(x) = 3$ នាំឱ្យបន្ទាត់ $y=3$ ជាអាស៊ីមតូតដេក ។

ខ. គណនាដេរីវេ $f'(x)$

គេមាន $f(x)=\dfrac{3(x-2)^2}{x^2-4x+3}$ កំនត់លើ $D_f = IR-\{1,3\}$

គេបាន $f'(x)=\dfrac{6(x-2)(x^2-4x+3)-3(2x-4)(x-2)^2}{(x^2-4x+3)^2}$

$$=\frac{6(x-2)(x^2-4x+3)-6(x-2)(x-2)^2}{(x^2-4x+3)^2}$$

$$=\frac{6(x-2)\left[(x^2-4x+3)-(x-2)^2\right]}{(x^2-4x+3)^2}=\frac{-6(x-2)}{(x^2-4x+3)^2}$$

ដូចនេះ $\boxed{f'(x)=\dfrac{-6x+12}{(x^2-4x+3)^2}}$ ។

គូសតារាងអថេរភាពនៃអនុគមន៍ f :

បើ $f'(x)=0$ គេបាន $-6x+12=0$ នាំឱ្យ $x=2$ ។

ចំពោះ $x=2$ គេបាន $f(2)=\dfrac{3(2-2)^2}{4-8+3}=0$ (ជាចំនុចបរមា)។

x	$-\infty$		1		2		3		$+\infty$
$f'(x)$			‖				‖		
$f(x)$		↗	‖	↗		↘	‖	↘	

គ. បង្ហាញថាបន្ទាត់ $x = 2$ ជាអក្ស័ឆ្លុះនៃក្រាប (c)

តាមរូបមន្ត $f(2a - x_0) = f(x_0)$ ដើម្បីស្រាយថាបន្ទាត់ $x = 2$

ជាអក្ស័ឆ្លុះនៃក្រាប (c) យើងគ្រាន់តែស្រាយឱ្យឃើញថា :

$f(4 - x_0) = f(x_0)$ គ្រប់ $x_0 \in D_f$ ។

គេមាន $f(x) = \dfrac{3(x-2)^2}{x^2 - 4x + 3}$ កំនត់លើ $D_f = IR - \{1,3\}$ ។

គេបាន $$f(4 - x_0) = \frac{3(4 - x_0 - 2)^2}{(4 - x_0)^2 - 4(4 - x_0) + 3}$$

$$f(4 - x_0) = \frac{3(2 - x_0)^2}{16 - 8x_0 + x_0^2 - 16 + 4x_0 + 3}$$

$$f(4 - x_0) = \frac{3(x_0 - 2)^2}{x_0^2 - 4x_0 + 3} = f(x_0)$$ ពិត ។

ដូចនេះ បន្ទាត់ $x = 2$ ជាអក្ស័ឆ្លុះនៃក្រាប (c) ។

ឃ. សង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយអរតូនរម៉ាល់ $(0, \vec{i}, \vec{j})$



លំហាត់ទី៣០

គេឱ្យអនុគមន៍ $f(x)=x+1-e^{x}$ កំនត់លើ IR ។

ក-គណនាលីមីតនៃអនុគមន៍ $f(x)$ កាលណា $x\to-\infty$ និង $x\to+\infty$ ។

ខ-បង្ហាញថាខ្សែកោង (c) តាងអនុគមន៍ $y=f(x)$

មានអាស៊ីមតូតទ្រេតមួយកាលណា$x\to-\infty$ ។

គ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

ដំណោះស្រាយ

ក-គណនាលីមីត

គេបាន $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}(x+1-e^{x})=-\infty$

ព្រោះ $\lim\limits_{x\to-\infty}(x+1)=-\infty$ និង $\lim\limits_{x\to-\infty} e^{x}=0$ ។

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x+1-e^{x})=\lim_{x\to+\infty}\left[e^{x}.\left(\frac{x+1}{e^{x}}-1\right)\right]=-\infty$$

ព្រោះ $\begin{cases}\lim\limits_{x\to+\infty} e^{x}=+\infty\\ \lim\limits_{x\to+\infty}\dfrac{x+1}{e^{x}}=0\end{cases}$

ខ-បង្ហាញថាខ្សែកោង (c) តាងអនុគមន៍ $y=f(x)$ មានអាស៊ីមតូតទ្រេតមួយះ

គេមាន $f(x)=x+1-e^{x}$ ដោយ $\lim\limits_{x\to-\infty} e^{x}=0$ នាំឱ្យបន្ទាត់ $y=x+1$

ជាអាស៊ីមតូតទ្រេតនៃក្រាប (c) ។

គ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$

គេមាន $f(x)=x+1-e^{x}$ នាំឱ្យ $f'(x)=1-e^{x}$

បើ $f'(0)=0$ គេបាន $e^{x}=1$ នាំឱ្យ $x=0$

ហើយ $f(0)=0+1-e^{0}=1-1=0$ ។

យើងអាចគូសតារាងអថេរភាពដូចខាងក្រោម :

x	$-\infty$		0		$+\infty$
$f'(x)$					
$f(x)$		↗		↘	



លំហាត់ទី៣១

គេឱ្យអនុគមន៍ f កំនត់លើ $]0,+\infty[$ ដោយ $f(x)=x-1-\ln x$

ក-គណនាលីមីត $\lim\limits_{x\to0^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ខ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

គ-ចូរសង់ក្រាប (c) តំនាងអនុគមន៍ $y=f(x)$ ក្នុងតំរុយអរតូណរម៉ាល់

ឃ-គណនាក្រឡាផ្ទៃខណ្ឌដោយខ្សែកោង (c) ជាមួយអក្ស័អាប់ស៊ីស ក្នុងចន្លោះ $[1,e]$ ។

ដំណោះស្រាយ

ក-គណនាលីមីត $\lim\limits_{x\to0^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$

$$\lim_{x\to0^+} f(x)=\lim_{x\to0^+}(x-1-\ln x)=+\infty$$ ព្រោះ $\lim\limits_{x\to0^+}\ln x=-\infty$ ។

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x-1-\ln x)=\lim_{x\to+\infty}\left[x\left(1-\frac{1}{x}-\frac{\ln x}{x}\right)\right]=+\infty$$

ព្រោះ $\lim\limits_{x\to+\infty}\left(1-\frac{1}{x}-\frac{\ln x}{x}\right)=1$ ។

ខ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$

គេមាន $f(x)=x-1-\ln x$ មានដែនកំនត់ $D=]0,+\infty[$

គេបាន $f'(x)=1-\frac{1}{x}=\frac{x-1}{x}$ បើ $f'(x)=\frac{x-1}{x}=0$ នាំឱ្យ $x=1$

និង $f(1)=0$ ។

x	0	1	$+\infty$
$f'(x)$			
$f(x)$	$\searrow$		$\nearrow$

គ-សង់ក្រាប (c) តំនាងអនុគមន៏ $y=f(x)$ ក្នុងតំរុយអរតូណរម៉ាល់



ឃ-គណនាក្រឡាផ្ទៃ

តាង S ជាផ្ទៃខណ្ឌដោយខ្សែកោង (c) ជាមួយអក្ស័អាប់ស៊ីសក្នុងចន្លោះ $[1,e]$

គេបាន $S=\int_1^e (x-1-\ln x).dx=\int_1^e (x-1).dx-\int_1^e \ln x.dx$

$$\int_1^e (x-1).dx=\left[\frac{x^2}{2}-x\right]_1^e=\left(\frac{e^2}{2}-e\right)-\left(\frac{1}{2}-1\right)=\frac{e^2}{2}-e+\frac{1}{2}=\frac{(e-1)^2}{2}$$

$$\int_1^e \ln x.dx=[x\ln x-x]_1^e=(e\ln e-e)-(1\ln 1-1)=e-e+1=1$$

ដូចនេះ $S=\frac{(e-1)^2}{2}-1=\frac{e^2-2e-1}{2}$ (ឯកតាផ្ទៃ) ។

លំហាត់ទី៣២

គេឱ្យអនុគមន៍ $f(x)=\frac{x+1}{e^{2x}}$ មានក្រាបតំនាង (c) ។

ក-គណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$ រួចបញ្ជាក់សមីការអាសុីមតូតដេកមួយនៃក្រាប (c) ។

ខ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

គ-ចូរសង់ក្រាប (c) ក្នុងតំរុយអរតូណរម៉ាល់ $(0,\vec{i},\vec{j})$ ។

ឃ-គណនាក្រឡាផ្ទៃ $S(\lambda)$ នៃប្លង់ខណ្ឌដោយក្រាប ជាមួយអក្ស័អាប់សុីសក្នុងចន្លោះ $[-1,\lambda]$,$(\lambda>-1)$ រួចទាញរក $\lim_{\lambda\to+\infty} S(\lambda)$ ។

ដំណោះស្រាយ

ក-គណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$ ៖

គេបាន $\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(\frac{x+1}{e^{2x}}\right)=\lim_{x\to-\infty}(x-1)e^{-2x}=-\infty$

ព្រោះ $\begin{cases}\lim_{x\to-\infty}(x-1)=-\infty\\ \lim_{x\to-\infty} e^{-2x}=+\infty\end{cases}$

និង $\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(\frac{x+1}{e^{2x}}\right)=\lim_{x\to+\infty}(x-1)e^{-2x}=0$

ព្រោះ $\begin{cases}\lim_{x\to+\infty}(x-1)=+\infty\\ \lim_{x\to+\infty} e^{-2x}=0\end{cases}$

នាំឱ្យបន្ទាត់ $y=0$ ជាសមីការអាសុីមតូតដេកមួយនៃក្រាប (c) ។

ខ-គូសតារាងអថេរភាពនៃអនុគមន៍ $f(x)$

គេមាន $f(x)=\frac{x+1}{e^{2x}}=(x+1).e^{-2x}$ កំនត់លើ IR

គេបាន $f'(x)=e^{-2x}-2(x+1).e^{-2x}$

$$=(-2x-1).e^{-2x}$$

បើ $f'(x)=(-2x-1).e^{-2x}=0$ នាំឱ្យ $x=-\frac{1}{2}$

ចំពោះ $x=-\frac{1}{2}$ នាំឱ្យ $f\left(-\frac{1}{2}\right)=\frac{e}{2}$ ។

តារាងអថេរភាព

x	$-\infty$	$-\frac{1}{2}$	$+\infty$
$f'(x)$			
$f(x)$	↗		↘

គ-សង់ក្រាប (c) ក្នុងតំរុយអរតូណរម៉ាល់ $(0,\vec{i},\vec{j})$



ឃ-គណនាក្រឡាផ្ទៃ $S(\lambda)$:

យើងបាន $S(\lambda)=\int_{-1}^{\lambda} f(x).dx=\int_{1}^{\lambda}(x+1).e^{-2x}.dx$

តាង $\begin{cases} u=x+1 \\ dv=e^{-2x}.dx \end{cases}$ នាំឱ្យ $\begin{cases} du=dx \\ v=-\dfrac{1}{2}.e^{-2x} \end{cases}$

$$S(\lambda)=\left[-\frac{1}{2}(x+1).e^{-2x}\right]_{-1}^{\lambda}+\frac{1}{2}\int_{-1}^{\lambda} e^{-2x}.dx$$

$$=-\frac{1}{2}(\lambda+1).e^{-2\lambda}-\frac{1}{4}\left[e^{-2x}\right]_{-1}^{\lambda}$$

$$=-\frac{1}{2}(\lambda+1).e^{-2\lambda}-\frac{1}{4}\left(e^{-2\lambda}-e^{2}\right)$$

$$=-\frac{\lambda}{2}e^{-2\lambda}-\frac{1}{2}e^{-2\lambda}-\frac{1}{4}e^{-2\lambda}+\frac{e^{2}}{4}$$

$$=\frac{e^{2}}{4}-\frac{1}{4}(2\lambda+3).e^{-2\lambda}$$

ដូចនេះ $\boxed{S(\lambda)=\dfrac{e^{2}}{4}-\dfrac{1}{4}(2\lambda+3).e^{-2\lambda}}$ (ឯកតាផ្ទៃ) ។

និង $\lim\limits_{\lambda\to+\infty} S(\lambda)=\lim\limits_{\lambda\to+\infty}\left[\dfrac{e^{2}}{4}-\dfrac{1}{4}(2\lambda+3).e^{-2\lambda}\right]=\dfrac{e^{2}}{4}$ ។

(ព្រោះ $\lim\limits_{\lambda\to+\infty}\dfrac{1}{4}(2\lambda+3).e^{-2\lambda}=0$) ។

លំហាត់ទី៣៣

គេឱ្យអនុគមន៍ $f(x)=(1-x).e^{x}-1$ កំនត់លើ IR ។

ក. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ f ។

ទាញបញ្ជាក់សញ្ញានៃអនុគន៍ $f(x)$ ។

ខ. គេឱ្យ g ជាអនុគមន៍ កំនត់លើ IR ដោយ $g(x)=(2-x).e^{x}+2-x$ ។

ចូរគណនាលីមីត $\lim\limits_{x\to-\infty} g(x)$ និង $\lim\limits_{x\to+\infty} g(x)$ ។

គ. គណនាដេរីវេ $g'(x)$ រួចបញ្ជាក់សញ្ញារបស់ $g'(x)$ ។

គូសតារាងអថេរភាពនៃ $g(x)$ ។

ឃ. ស្រាយបញ្ជាក់ថាបន្ទាត់ $(d): y=2-x$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C)

តាងអនុគមន៍ g កាលណា $x\to-\infty$ ។

សិក្សាទីតាំងធៀបរវាងខ្សែកោង (C) និងបន្ទាត់ (d) ។

ង.សរសេរសមីការបន្ទាត់ (T) ប៉ះនឹងខ្សែកោង (C) ហើយស្របនឹងបន្ទាត់ (d)

ច. កំនត់កូអរដោនេចំនុចរបត់ I របស់ខ្សែកោង (C) ។

ឆ. ចូរសង់ក្រាប (C) បន្ទាត់ (T) និង (d) ក្នុងតំរុយអរតូណរម៉ាល់ $(0,\vec{i},\vec{j})$ ។

ដំណោះស្រាយ

ក. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ f

គេមាន $f'(x)=(1-x)'.e^{x}+(e^{x})'.(1-x)$

$$= -e^x + e^x(1-x)$$
$$= -e^x + e^x - x.e^x$$
$$= -x.e^x$$

បើ $f'(x) = -x.e^x = 0$ នាំអោយ $x = 0$ ។

ចំពោះ $x = 0$ គេបាន $f(0) = (1-0).e^0 - 1 = 0$ ។

គណនាលីមីតៈ

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty}\left[(1-x).e^x - 1\right] = -1$$

និង $\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left[(1-x).e^x - 1\right] = -\infty$

x	$-\infty$	0	$+\infty$
$f'(x)$			
$f(x)$	↗		↘

ទាញបញ្ជាក់សញ្ញានៃអនុគមន៍ $f(x)$:

តាមតារាងខាងលើគេទាញបាន $\forall x \in IR : f(x) \le 0$ ។

ខ គណនាលីមីត $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$:

គេបាន $\lim_{x\to-\infty} g(x) = \lim_{x\to-\infty}\left[(2-x).e^x + (2-x)\right] = +\infty$

ព្រោះ $\begin{cases} \lim_{x\to-\infty}(2-x) = +\infty \\ \lim_{x\to-\infty}(e^x) = 0 \end{cases}$

គេបាន $\lim_{x\to+\infty} g(x) = \lim_{x\to+\infty}\left[(2-x).e^x + (2-x)\right] = -\infty$

ព្រោះ $\begin{cases} \lim\limits_{x\to+\infty}(2-x) = -\infty \\ \lim\limits_{x\to+\infty}(e^x) = +\infty \end{cases}$

គ. គណនាដេរីវេ $g'(x)$ រួចបញ្ជាក់សញ្ញារបស់ $g'(x)$៖

គេមាន $g(x) = (2-x).e^x + 2 - x = (2-x)(e^x+1)$

គេបាន
$$\begin{aligned} g'(x) &= (2-x)'(e^x+1) + (e^x+1)'(2-x) \\ &= -(e^x+1) + e^x.(2-x) \\ &= -e^x - 1 + 2e^x - x.e^x = e^x - x.e^x - 1 \\ &= (1-x).e^x - 1 \end{aligned}$$

ដូចនេះ $\boxed{g'(x) = (1-x).e^x - 1}$

ម្យ៉ាងទៀតដោយ $g'(x) = (1-x).e^x - 1 = f(x)$

ហើយគេមាន $\forall x \in IR : f(x) \le 0$

ដូចនេះ $\forall x \in IR : g'(x) \le 0$ ។

គូសតារាងអថេរភាពនៃ $g(x)$៖

x	$-\infty$	0	$+\infty$
$g'(x)$			
$g(x)$		$\searrow$	

ចំពោះ $x = 0$ នាំអោយ $g(0) = 4$

ឃ. ស្រាយបញ្ជាក់ថាបន្ទាត់ $(d): y = 2 - x$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C)

គេមាន $\begin{cases} (C): g(x) = (2-x).e^{x} + 2 - x \\ (d): y = 2 - x \end{cases}$

គេបាន $g(x) - y = (2-x).e^{x}$

ដោយគេមាន $\lim\limits_{x\to-\infty}[g(x) - y] = \lim\limits_{x\to-\infty}[(2-x).e^{x}] = 0$

ដូចនេះ បន្ទាត់ $(d): y = 2 - x$ ជាអាស៊ីមតូតទ្រេតនៃក្រាប (C) ។

សិក្សាទីតាំងធៀបរវាងខ្សែកោង (C) និងបន្ទាត់ (d) ៖

គេមាន $g(x) - y = (2-x).e^{x}$ មានសញ្ញាដូច $2 - x$

ព្រោះ $\forall x \in IR : e^{x} > 0$

តារាងសញ្ញានៃ $g(x) - y = (2-x).e^{x}$

x	$-\infty$	2	$+\infty$
$g(x) - y$	$+$		$-$

-ចំពោះ $x \in]-\infty, 2[$ ខ្សែកោង (C) នៅពីលើបន្ទាត់ (d) ។

-ចំពោះ $x = 2$ ខ្សែកោង (C) ប្រសព្វបន្ទាត់ (d) ត្រង់ចំនុច $A(2,0)$ ។

-ចំពោះ $x \in]2, +\infty[$ ខ្សែកោង (C) នៅពីក្រោមបន្ទាត់ (d) ។

ង. សរសេរសមីការបន្ទាត់ (T) ប៉ះនឹងខ្សែកោង (C) ហើយស្របនឹងបន្ទាត់ (d) ៖

តាង $M_0(x_0, y_0)$ ជាចំនុចប៉ះរវាងបន្ទាត់ (T) ជាមួយ (C)

តាមរូបមន្ត $(T): y - y_0 = y'_0.(x - x_0)$

ដោយ $(T)//(d): y = 2 - x$ នាំឱ្យ $y'_0 = -1$

តែ $y'_0 = g'(x_0) = (1 - x_0)e^{x_0} - 1$

គេទាញបាន $(1 - x_0)e^{x_0} - 1 = -1$ នាំឱ្យ $x_0 = 1$

ហើយ $y_0 = g(x_0) = e + 1$

គេបាន $(T): y - (e + 1) = -1.(x - 1)$

ដូចនេះ $(T): y = -x + e + 2$ ។

ច. កំនត់កូអរដោនេចំនុចរបត់ I របស់ខ្សែកោង (C) ៖

គេមាន $g'(x) = (1 - x).e^x - 1 = f(x)$

គេបាន $g''(x) = f'(x) = -x.e^x$ មានឫស $x = 0$ ។

ចំពោះ $x = 0$ គេបាន $g(0) = 4$ ។

តារាងសិក្សាសញ្ញានៃ $g''(x) = -x.e^x$

x	$-\infty$	0	$+\infty$
$g''(x)$			
$g(x)$			

ដោយត្រង់ចំនុច $x = 0$ កន្សោម $g''(x)$ ប្តូរសញ្ញាពី $(+)$ ទៅ $(-)$

នាំឱ្យ $I(0,4)$ ជាចំនុចរបត់នៃក្រាប ។

ឆ. សង់ក្រាប (C) បន្ទាត់ (T) និង (d)ក្នុងតំរុយអរតូណរម៉ាល់ ៖



✍✍✍✍✍